សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the
Promotion and Defense of
Human Rights




# កុមារដែលត្រូវបានបញ្ជូនចេញពីប្រទេសកម្ពុជាដោយលួចលាក់៖

## ការក្លែងបន្លំ និងអំពើដែលត្រូវបានអះអាងថាជាអំពើពុករលួយក្នុងប្រព័ន្ធសុំកូនអន្តរប្រទេស


របាយការណ៍សង្ខេប
ចេញផ្សាយ ខែមីនា ឆ្នាំ២០១៨

# កុមារដែលត្រូវបានបញ្ជូនចេញពីប្រទេសកម្ពុជាដោយលួចលាក់៖

## ការក្លែងបន្លំ និងអំពើដែលត្រូវបានអះអាងថាជាអំពើពុករលួយក្នុងប្រព័ន្ធសុំកូនអន្តរប្រទេស

របាយការណ៍សង្ខេបចេញផ្សាយ ខែមីនា ឆ្នាំ២០១៨


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅ តាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

ប្រវត្តិនៃស្មុំកូនអន្តរប្រទេសនៅកម្ពុជា ទំព័រ៣

ករណីសំខាន់ៗដែលត្រូវបានឃ្លាំមើលនៅឆ្នាំ២០១៧ ទំព័រ៨

សំណាងការខូចខាតពីសកម្មភាពស្មុំកូនដោយក្លែងបន្លំ ទំព័រ១៦

សេចក្តីសន្និដ្ឋាន ទំព័រ១៧

អនុសាសន៍ ទំព័រ១៨




រូបភាពទំព័រមុខ៖ ម្តាយ និងកូនៗ
ដែលកូនបួននាក់ក្នុងចំណោមនោះ ត្រូវបានគេយកទៅចិញ្ចឹមនៅ
ប្រទេសអ៊ីតាលីចន្លោះឆ្នាំ ២០០៨-០៩ (សូមមើលករណីទី៣)

# សេចក្តីផ្តើម

ចាប់ពីចុងទសវត្សរ៍ ឆ្នាំ១៩៨០ ដល់ ឆ្នាំ២០០៩ ប្រទេសកម្ពុជា បានអនុវត្តប្រព័ន្ធសុំកូនអន្តរប្រទេសដែលអនុញ្ញាតឲ្យមានកុមាររាប់ពាន់នាក់ ត្រូវបានគ្រួសារជាជនបរទេសសុំយកទៅចិញ្ចឹម នៅក្រៅប្រទេស។ អំឡុងពេលនោះ មានភស្តុតាងស្តីពីការបន្លំ និងអំពើដែលត្រូវបានគេអះអាង ថាជាអំពើពុករលួយយ៉ាងច្រើន ដែលពាក់ព័ន្ធនឹងការសុំយកកុមារចេញ ដោយគ្មានការយល់ព្រមពីម្តាយឪពុកបង្កើតរបស់អ្នកទាំងនោះ។ ភស្តុតាងទាំងនេះបានធ្វើឲ្យសហរដ្ឋអាមេរិក និង បណ្តាប្រទេសមួយចំនួននៅសហគមន៍អឺរ៉ុប បានសម្រេចផ្អាកសុំកូនពីប្រទេសកម្ពុជា។ ជាលទ្ធផល រាជរដ្ឋាភិបាលកម្ពុជាផ្ទាល់ ក៏ធ្លាប់បានផ្អាកជាបណ្តោះអាសន្ននូវការសុំកូនទៅចិញ្ចឹម នៅបរទេស ជាច្រើនដងមកហើយដែរ ដើម្បីកែលម្អនីតិវិធី។ ការផ្អាកចុងក្រោយបំផុត គឺនៅឆ្នាំ២០០៩ ហើយការផ្អាកនេះ បានបន្តមកដល់សព្វថ្ងៃ។

បើទោះជាមានការកែប្រែមួយចំនួន ទៅលើច្បាប់ស្តីពីសុំកូនអន្តរប្រទេសក្តី វិធានការអនុវត្តជាក់ស្តែងមានចំនួនតិចតួចណាស់ ដែលត្រូវបានធ្វើឡើងដើម្បីធានាថាការបន្លំ និងអំពើដែលត្រូវបានគេអះអាងថា ជាអំពើពុករលួយ នឹងមិនកើតមានឡើងម្តងទៀត។ លើសពីនេះ អាជ្ញាធរកម្ពុជានៅមិនទាន់ចាត់ វិធានការស៊ើបអង្កេតឲ្យបានម៉ត់ចត់ និង ផ្តន្ទាទោសតាមផ្លូវតុលាការ ចំពោះការរំលោភបំពាន ទាក់ទងនឹងសុំកូននេះនៅឡើយទេ។ ជាលទ្ធផល បុគ្គលិកមជ្ឈមណ្ឌលកុមារកំព្រា និងមន្ត្រីរដ្ឋាភិបាលមួយចំនួន ដែលធ្លាប់បានអនុវត្តការរំលោភបំពានកន្លងមក នៅមិនទាន់ត្រូវបានយកមកផ្តន្ទាទោសនៅឡើយទេ។

ទោះជាយ៉ាងនេះក្តី អាជ្ញាធរកម្ពុជា បានបញ្ជាក់ជាច្រើនលើកមកហើយ ពីឆន្ទៈរបស់ខ្លួន ដើម្បីបើកដំណើរការឡើងវិញ នូវការសុំកូនអន្តរប្រទេស ហើយអង្គការលីកាដូ យល់ឃើញថា សេចក្តីសម្រេចឲ្យបើកដំណើរការឡើងវិញ នឹងអាចកើតឡើង នាពេលឆាប់ៗនេះ។[១] អង្គការលីកាដូ ជឿជាក់ថា ប្រសិនបើសេចក្តីសម្រេច នឹងត្រូវបានធ្វើឡើង នោះនឹងមិនមានវិធានការអ្វី ដើម្បីការពារពីការកើតឡើងវិញ នូវអំពើក្លែងបន្លំ និងអំពើដែលត្រូវបានគេអះអាងថា ជាអំពើពុករលួយនោះទេ ហើយនឹងមានហានិភ័យខ្ពស់ ដែលការរំលោភបំពានពីអតីតកាលនឹងបន្តកើតមានឡើងនៅថ្ងៃអនាគត។

ផលប៉ះពាល់ ដែលកើតពីការមិនអាចដោះស្រាយបញ្ហាខាងលើនេះបាន ពីសំណាក់អាជ្ញាធរកម្ពុជា បានបង្ហាញឲ្យឃើញកាន់តែច្បាស់ ដល់អង្គការ លីកាដូ នៅឆ្នាំ២០១៧ នៅពេលដែលស្ត្រីចំនួនបីនាក់ ដែលកូនៗរបស់អ្នកទាំងនោះ ត្រូវបានគេយកទៅចិញ្ចឹមនៅបរទេស នៅពេលវេលាខុសៗគ្នា ក្នុងរយៈពេល ១៥ឆ្នាំ ចុងក្រោយនេះ។ នៅក្នុងករណីទីមួយ កុមារម្នាក់ត្រូវបានគេយកទៅចិញ្ចឹមនៅ សហរដ្ឋអាមេរិក។ ហើយក្នុងករណីទីពីរ កុមារពីរនាក់ ត្រូវបានគេយកទៅចិញ្ចឹម នៅប្រទេសអូទ្រីស។ ចំណែកឯករណីទីបី កុមារបួននាក់ ត្រូវបានគេសុំយកទៅចិញ្ចឹមនៅប្រទេសអ៊ីតាលី ។ កុមារទាំងប្រាំពីររូបនេះមានអាយុចន្លោះ ពី៣ ទៅ ៩ឆ្នាំ។ ម្តាយរបស់កុមារទាំង នោះ នៅមិនទាន់ទទួលបាន ដំណឹងណាមួយពីកូនៗអ្នកទាំងនោះ នៅក្នុងដំណាក់កាលអន្តរាគមន៍ របស់អង្គការ លីកាដូ នោះទេ ហើយពួកគេចង់ដឹងពីសុខទុក្ខរបស់កូនៗ។

**ដោយផ្អែកលើប្រវត្តិនៃសុំកូនអន្តរប្រទេស នៅក្នុងប្រទេសកម្ពុជា និងចំនួនកុមារដែលត្រូវបានគេយកទៅចិញ្ចឹម បញ្ហានៃការបញ្ជូនកុមារចេញពីប្រទេសកម្ពុជាដោយលួចលាក់នេះ ប្រហែលមិនមែនកើតឡើងតែក្នុងករណីទាំងបីនេះទេ ហើយប្រហែលជាកើតមានឡើង លើក្រុមគ្រួសាររាប់រយផ្សេងទៀតនៅកម្ពុជា បើទោះបីជាមិនដល់រាប់ពាន់គ្រួសារក៏ដោយ។**

ស្ត្រីដែលជាម្តាយទាំងបីនាក់ មានជីវភាពក្រខ្សត់យ៉ាងខ្លាំង នៅពេលដែលអ្នកទាំងនោះបានយកកូនៗទៅផ្ញើនៅមជ្ឈមណ្ឌលកុមារកំព្រា និងនៅពេលដែលការសុំកូនកំពុងត្រូវបានធ្វើឡើង។ ក្នុងករណីចំនួនពីរ ស្ត្រីជាម្តាយធ្វើបែបនេះ គឺដើម្បីចង់ឲ្យកូនៗពួកគេ បានទៅសាលារៀន។

[១] មន្ត្រីនៅក្រសួងសង្គមកិច្ច បានប្រាប់បុគ្គលិកអង្គការលីកាដូជាច្រើនដង រវាងពីខែមិនា ដល់តុលា ឆ្នាំ២០១៧



មជ្ឈមណ្ឌលកុមារកំព្រានៅរាជធានីភ្នំពេញ ជាកន្លែងដែលកុមារបួននាក់ធ្លាប់បានរស់នៅ និងត្រូវបានគេយកចេញទៅចិញ្ចឹមនៅប្រទេសអ៊ីតាលី (សូមមើលករណីទី៣)

ចំណែកករណីទីបីគឺ ដោយសារកុមារនោះ មានជំងឺធ្ងន់ធ្ងរខ្លាំង ហើយត្រូវការការថែទាំ ឲ្យបានដិតដល់ដែលម្ដាយកូននោះមិនមានលទ្ធភាពផ្ដល់ឲ្យបាន ពីព្រោះស្ត្រីជាម្ដាយជាកម្មកររោងចក្រកាត់ដេរ។ មិនមានករណីណាមួយដែលម្ដាយបានបោះបង់កូនៗខ្លួននោះទេ ហើយក៏គ្មានករណីណាដែលម្ដាយទាំងនោះ បានផ្ដល់សិទ្ធិឲ្យគេ យកកូនទៅចិញ្ចឹមនោះដែរ។ អង្គការលីកាដូ បានឃ្លាំមើលលើករណីទាំងបីនេះ និងបានរកឃើញថា សកម្មភាពសុំកូនទាំងនេះ ត្រូវបានធ្វើឡើង ដោយការក្លែងបន្លំ និងមិនខ្វល់ពីសិទ្ធិ និងអារម្មណ៍របស់ក្រុមគ្រួសាររបស់កុមារ។

ដោយផ្អែកលើ ប្រវត្តិនៃសុំកូនអន្តរប្រទេស នៅក្នុងប្រទេសកម្ពុជា និងចំនួនកុមារ ដែលត្រូវបានគេយកទៅចិញ្ចឹមបញ្ហា នៃការបញ្ជូនកុមារចេញពីប្រទេសកម្ពុជាដោយលួចលាក់នេះ ប្រហែលមិនមែនកើតឡើងតែក្នុងករណីទាំងបីនេះទេ ហើយប្រហែលជាកើតមានឡើងលើក្រុមគ្រួសាររាប់រយផ្សេងទៀត នៅកម្ពុជា បើទោះបីជាមិនដល់រាប់ពាន់គ្រួសារក៏ដោយ។ ហេតុផលដែលគ្រួសារជាច្រើនទាំងនោះ មិនមករកជំនួយ អាចដោយសារអ្នកទាំងនោះ មិនដឹងថាតើទៅរកជំនួយនៅកន្លែងណា ឬក៏មិនជឿថា ជនល្មើសនឹងអាចនាំមក ផ្ដន្ទាទោសបាន ហើយកូនរបស់អ្នកទាំងនោះ នឹងអាចត្រឡប់មកវិញបាន ឬក៏អត់។

ស្ត្រីទាំងបីរូប ដែលមកសុំជំនួយពីអង្គការ លីកាដូ នៅតែគិតពីកូនៗរបស់អ្នកទាំងនោះ ជានិច្ច។ ការបាត់បង់នេះគឺជា បន្ទុកមួយដ៏សែនធ្ងន់ធ្ងរ មកលើអ្នកទាំងនោះ ហើយការខ្វះខាតព័ត៌មាន ពីសុខទុក្ខរបស់កូន ធ្វើឲ្យម្ដាយទាំងនេះ ឈឺចាប់ជារៀងរាល់ថ្ងៃ។ ឥឡូវនេះ អ្នកទាំងនោះយល់ច្បាស់ថា កូនៗនឹងមិនត្រឡប់មករស់នៅក្នុងប្រទេសកម្ពុជាវិញនោះឡើយ ក៏ប៉ុន្តែ ម្ដាយទាំងនោះ នៅតែចង់ភ្ជាប់ទំនាក់ទំនង ជាមួយកូនឡើងវិញ យ៉ាងខ្លាំង ហើយយ៉ាងតិចណាស់ ក៏ចង់ទទួលបាននូវដំណឹង ពីសុខទុក្ខរបស់កូនៗដែរ។ អង្គការ លីកាដូ កំពុងជួយស្ត្រីទាំងនេះឲ្យអាចសម្រេចបំណងបាន ដោយការទាក់ទង ជាមួយអាជ្ញាធរពាក់ព័ន្ធ និងភាគីផ្សេងទៀតទាំងក្នុងប្រទេសកម្ពុជា និងនៅបរទេស។ នេះគឺជាដំណើរការ នៃការដោះស្រាយបញ្ហាមួយ ដែលលំបាក និង យឺតប៉ុន្តែកំពុងត្រូវបានបន្តដោះស្រាយនៅឡើយ។ សុំកូនដោយការក្លែងបន្លំ គឺជាបញ្ហាមួយ ដែលតែងតែកើតមាន ឡើងនៅពេលដែលមានសកម្មភាព សុំកូនអន្តរប្រទេសកើតឡើង។[២] ទោះបីជាបែបនេះក៏ដោយ ហើយទោះជាមានច្បាប់អន្តរជាតិចែង អំពីសុំកូនអន្តរប្រទេសក៏ដោយ ក៏នៅមិនទាន់មាននីតិវិធី ដែលបានព្រមព្រៀង និងច្បាស់លាស់ណាមួយ ដើម្បីដោះស្រាយបញ្ហាក្លែងបន្លំ ជាច្រើនករណីដែលបានកើតមានឡើង មិនថានៅប្រទេសកម្ពុជា ឬអន្តរជាតិនោះទេ។ បញ្ហានេះបង្កជាភាពលំបាកយ៉ាងខ្លាំងសម្រាប់ ជនរងគ្រោះទាំងនោះ ក្នុងការទទួលបាននូវសំណាងណាមួយ។

**ក៏នៅមិនទាន់មាននីតិវិធី
ដែលបានព្រមព្រៀង និង ច្បាស់លាស់
ណាមួយ ដើម្បី ដោះស្រាយ បញ្ហាក្លែងបន្លំជា
ច្រើនករណីដែលបានកើត មានឡើង
មិនថានៅប្រទេសកម្ពុជា ឬអន្តរជាតិនោះទេ។
បញ្ហា នេះបង្កជាភាព លំបាក
យ៉ាងខ្លាំងសម្រាប់ជនរងគ្រោះ ទាំងនោះ
ក្នុងការទទួលបាននូវសំណាងណាមួយ។**

[២] ជាឧទាហរណ៍សូមមើលការងាររបស់លោក David Smolin តាមរយៈ https://works.bepress.com/david_smolin/.

របាយការណ៍នេះ ធ្វើសេចក្តីសន្និដ្ឋានដោយភ្ជាប់ជាមួយនូវអនុសាសន៍ ជូនរាជរដ្ឋាភិបាលកម្ពុជា និង ជូនរដ្ឋាភិបាលនៃប្រទេស ដែលបានទទួលយកកុមារកម្ពុជា ដើម្បីឲ្យអាជ្ញាធរនៃរដ្ឋាភិបាលប្រទេសទាំងនោះ ដាក់ចេញនូវនីតិវិធី សម្រាប់ជួយដល់ក្រុមគ្រួសារទាំងនោះ ឲ្យអ្នកទាំងនោះរៀបរាប់រឿងរ៉ាវរបស់ពួកគេ ជួយសម្របសម្រួលទំនាក់ទំនងរវាងម្តាយឪពុកបង្កើត និងកូនដែលត្រូវបានគេយកទៅចិញ្ចឹម ប្រសិនបើភាគីទាំងសងខាងចង់ធ្វើការទាក់ទងគ្នា និងដាក់បុគ្គលដែលបានប្រព្រឹត្តរំលោភបំពានឲ្យទទួលខុសត្រូវ ទទួលស្គាល់នូវកំហុសដែលបានប្រព្រឹត្តចំពោះ ម្តាយឪពុកបង្កើត កូនដែលគេយកទៅចិញ្ចឹម និង ម្តាយឪពុកចិញ្ចឹម ហើយចុងក្រោយផ្តល់នូវការជួសជុលជាសំណងឲ្យបានសមរម្យ។

ចុងក្រោយ អាជ្ញាធរទាំងនោះត្រូវធានាថា នឹងមិនមានសុំកូនអន្តរប្រទេស កើតឡើងជាថ្មីទៀតទេ លុះត្រាតែមានប្រព័ន្ធនៃការដោះស្រាយបញ្ហា និង ជួសជុលជាសំណងសមរម្យ ត្រូវបានអនុវត្ត ហើយវិធានការម៉ត់ចត់ត្រូវបានបង្កើតឡើង ដើម្បីធានាថា ការរំលោភបំពាននិងការរងទុក្ខលំបាកកាលពីអតីតកាល នឹងមិនអាចកើតឡើងចំពោះគ្រួសារនៅជំនាន់ក្រោយៗនោះទៀតទេ។

# ប្រវត្តិនៃសុំកូនអន្តរប្រទេសនៅកម្ពុជា

សកម្មភាពសុំកូនកម្ពុជា យកទៅចិញ្ចឹមនៅក្រៅប្រទេស បានចាប់កើតមានឡើង នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ហើយទសវត្សរ៍ក្រោយមកទៀត ចំនួនកុមារដែលត្រូវបាន គេយកទៅចិញ្ចឹម នៅបរទេស បានកើនឡើងយ៉ាងខ្លាំង។ យោងតាមរបាយការណ៍ ក្រសួងសង្គមកិច្ច ចន្លោះពីឆ្នាំ១៩៨៧ ដល់២០០៩ មានកុមារចំនួន៣,៦៩៦ នាក់ ត្រូវបានគេនាំយកចេញពី ប្រទេសកម្ពុជា ដើម្បីយកទៅចិញ្ចឹម[៣] ហើយតួលេខនេះ អាចមានច្រើន ជាងនេះ ដោយសារតែ ការកត់ត្រាទិន្នន័យ មិនទាន់មានប្រព័ន្ធច្បាស់លាស់ ហើយការសុំកូនមួយចំនួន មិនត្រូវបានធ្វើឡើង តាមរយៈក្រសួងសង្គមកិច្ច នោះទេ។ ក្តីបារម្ភអំពីការអនុវត្តខុសច្បាប់ជាច្រើន ដូចជាការលក់ទារកដែលមិនកំព្រាម្តាយឪពុក និងអំពើ ដែលត្រូវបានគេអះអាងថាជាអំពើពុករលួយ ដែលត្រូវបានប្រព្រឹត្តដោយមន្ត្រីរាជការ បានកើនឡើងយ៉ាងឆាប់រហ័ស ហើយសកម្មភាពសុំកូននេះ ត្រូវបានផ្អាកជាបណ្តោះអាសន្ន ជាច្រើនដងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ដោយសារតែ បញ្ហាទាំងនេះបានកើតឡើង។[៤]




ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅរាជធានីភ្នំពេញ

[៣] គេហទំព័រអាជ្ញាធរកណ្តាលកម្ពុជាសម្រាប់ការសុំកូនឆ្លងដែន តាមរយៈ http://www.icaa-cambodia.com.kh/2017/03/28/our-history/

[៤] ព័ត៌មានជាភាសាអង់គ្លេស ពីកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៦ ដែលមានចំណងជើងថា៖ Adoptions: Saving Lives or Selling Young Souls, Jason Barber, http://www.phnompenhpost.com/national/adoptions-saving-lives-or-selling-young-souls.

ករណីជាច្រើន ដែលត្រូវបានឃ្លាំមើលដោយ អង្គការ លីកាដូ កាលពីចុងទសវត្សរ៍ឆ្នាំ១៩៩០ និងដើម ទសវត្សរ៍ឆ្នាំ២០០០ បានលាតត្រដាង ពីភ័ស្តុតាងនៃការ ទិញទារក និងការក្លែងបន្លំឯកសារ ដែលចាំបាច់ ដើម្បីឲ្យ អាចធ្វើសកម្មភាពសុំកូនអន្តរប្រទេសបាន។[៥] ករណីភាគ ច្រើន កើតឡើងចំពោះស្ត្រីក្រីក្រ ដែលភាគច្រើននៃស្ត្រីទាំង នោះជាស្ត្រីមេម៉ាយ ឬលែងលះស្វាមី និងរស់នៅយ៉ាង លំបាក ក្នុងការចិញ្ចឹមបីបាច់ទារក ឬកុមារតូចៗ។ ស្ត្រីទាំង នោះ តែងតែត្រូវបាន ទាក់ទងដោយជនទីបី ដែលជា មេខ្យល់ ដែលជននោះ បានណែនាំថា កូនៗរបស់ស្ត្រី ទាំងនោះ អាចទៅរស់នៅក្នុងមណ្ឌលកុមារកំព្រា ដើម្បីឲ្យ កូនៗទាំងនោះ ទទួលបានការថែទាំ បានដិតដល់។ ជននោះបានប្រាប់ម្តាយទាំងនោះថា ពួកគេអាចទៅលេង កូនៗបាន ហើយប្រាប់ទៀតថា ពេលដែលស្ត្រីទាំងនោះ មានជីវភាពធូរធារ ពួកគេអាចទៅយកកូនៗទាំងនោះមក ចិញ្ចឹមវិញបាន។ កុមារតូចៗទាំងនោះ បន្ទាប់មកត្រូវបាន គេយកទៅដាក់ នៅមណ្ឌលកុមារកំព្រា ដែលនៅទីនោះ មាន ក្រុមអ្នកសម្របសម្រួល សកម្មភាពសុំកូន ទៅ ទាក់ទង។ អ្នកសម្របសម្រួលទាំងនេះ ភាគច្រើន ធ្វើការ ឲ្យភ្នាក់ងារ សុំកូនអន្តរប្រទេស។ មណ្ឌលកុមារកំព្រា ដើរតួ ជាអ្នករត់ឯកសារចាំបាច់ សម្រាប់ការសុំកូន ជាមួយ អាជ្ញាធរមូលដ្ឋាន ដូចជា មេភូមិ ដែលទទួលបានសំណូក ជាថ្នូរនឹងការចេញឯកសារទាំងនោះ។ លិខិតឯកសារបែប នេះ ភាគច្រើន គឺត្រូវបានធ្វើឡើង ដោយបញ្ជាក់ថា កុមារ ទាំងនោះ ត្រូវបានម្តាយឪពុក បោះបង់ចោល ហើយថា អត្តសញ្ញាណ របស់ម្តាយឪពុកក្មេង មិនត្រូវបានគេ ស្គាល់។ សំបុត្រកំណើតក្លែងក្លាយ ដែលដាក់ឈ្មោះ និង ព័ត៌មានគ្រួសារថ្មី ត្រូវបានបង្កើតឡើង ដែលធ្វើឲ្យមាន ការលំបាកស្មុគស្មាញក្នុង ការស្រាវជ្រាវរកប្រវត្តិដើមរបស់ កុមារនៅពេលក្រោយ។

កាលពីឆ្នាំ២០០១ ស្ត្រីខ្មែរពីរនាក់ ដែលមានជីវភាព ក្រីក្រ និងបានលែងលះស្វាមី ក្រោយពេលបានប្រគល់កូន ទៅឲ្យមេខ្យល់ម្នាក់ បានមកទាក់ទងអង្គការ លីកាដូ ។ ស្ត្រីទាំងនោះ ត្រូវបានបុគ្គលជាមេខ្យល់សន្យាថា កូនៗ របស់ស្ត្រីទាំងនោះ នឹងត្រូវយកទៅដាក់ឲ្យរស់នៅក្នុង មណ្ឌលកុមារកំព្រាមួយ នៅរាជធានីភ្នំពេញ ជាកន្លែង ដែលស្ត្រីជាម្តាយទាំងនោះអាចទៅមើល និងសួរសុខទុក្ខ កូនជាប្រចាំបាន។ ក្រោយមក ពេលម្តាយទាំងពីរ បាន ព្យាយាមទៅសួរសុខទុក្ខកូនរបស់អ្នកទាំងនោះ ក៏ប៉ុន្តែ អ្នកទាំងពីរ មិនត្រូវបានអនុញ្ញាតឲ្យជួបនោះទេ។ តាមរយៈ ការឃ្លាំមើល កុមារទាំងពីរ ត្រូវបានរកឃើញថា បាននៅ ក្នុងមណ្ឌលកុមារកំព្រាឯកជនមួយ ដែលគ្រប់គ្រងដោយ អ្នកសម្របសម្រួលសកម្មភាព សុំកូន។ អ្នកសម្រប សម្រួលនោះ គឺជាអ្នកផ្គត់ផ្គង់កុមារ ឲ្យទៅទីផ្សារនៅ សហរដ្ឋអាមេរិក។ ជាសំណាងល្អ កុមារទាំងពីរ ត្រូវបាន ប្រគល់ទៅឲ្យម្តាយបង្កើតរបស់ពួកគេវិញ។ អង្គការលីកាដូ បានជូនដំណឹងទៅស្ថានទូតសហរដ្ឋអាមេរិក អំពីករណី នេះ ហើយស្ថានទូតក៏បានបញ្ជាក់មកវិញថា កុមារម្នាក់ក្នុង ចំណោមកុមារទាំងពីរនេះ កំពុងស្ថិតនៅក្នុងដំណាក់កាល រង់ចាំក្នុងការ ដាក់ពាក្យស្នើសុំសុំកូនទៅសហរដ្ឋអាមេរិក។ ឯកសាររបស់កុមារ បានបញ្ជាក់ថា កុមារនេះជាក្មេងដែល ត្រូវគេបោះបង់ចោល ហើយអត្តសញ្ញាណរបស់ម្តាយឪពុក កុមារមិនត្រូវបានគេស្គាល់។

**ផ្អែកតាមកិច្ចសម្ភាសន៍ជាមួយម្តាយឪពុក ចិញ្ចឹម បានបង្ហាញពីអត្រាតម្លៃផ្សេងៗជាច្រើន នៅក្នុងដំណើរការសុំកូននៅកម្ពុជា និង បាន រកឃើញថា មានការចំណាយក្រៅផ្លូវការកើតមាន ឡើង នៅក្នុងដំណើរការសុំកូន។ របាយការណ៍ បានបង្ហាញថា មានការបង់ប្រាក់ចន្លោះពី២,០០០ ទៅ៤,០០០ ដុល្លារសហរដ្ឋអាមេរិក ជូនក្រសួង ការបរទេស ៥០០ដុល្លារសហរដ្ឋអាមេរិក ជូន ក្រសួងសង្គមកិច្ច និងច្រើនរយដុល្លារជូនទីស្តីការ គណៈរដ្ឋមន្ត្រី។**

ជាលទ្ធផល ចំពោះករណីនេះ សហរដ្ឋអាមេរិក បាន ផ្អាកសុំកូនពីប្រទេសកម្ពុជា នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០១។ ការសម្រេចផ្អាកសុំកូននេះ បានកើតឡើង ក្រោយពេល មាន ការត្រួតពិនិត្យដោយការិយាល័យអន្តោប្រវេសន៍ និង សញ្ជាតូបនីយកម្មរបស់សហរដ្ឋអាមេរិក ដែលបានរក ឃើញថា មានភាពមិនស៊ីចង្វាក់គ្នា និងការខ្វះខាតកំណត់ ត្រាឯកសារឲ្យបានត្រឹមត្រូវ ពីខាងមណ្ឌលកុមារកំព្រា នៅកម្ពុជា ហើយនិងឯកសារមួយចំនួនស្តីពីស្ថានភាព របស់កុមារ ដែលត្រូវបានរៀបចំ សម្រាប់ការសុំកូនយកទៅ ចិញ្ចឹមនៅបរទេស មានភាពស្រពិចស្រពិល។[៦] កាលពីឆ្នាំ ២០០២ បន្ទាប់ពីការផ្អាកសុំកូន មន្ត្រីអនុវត្តអន្តោប្រវេសន៍ និងពន្ធគយរបស់សហរដ្ឋអាមេរិកបានបើកការស៊ើបអង្កេត នៅក្នុងប្រទេសកម្ពុជា ពីការពាក់ព័ន្ធដែលអាចកើតមាន

[៥] របាយការណ៍អង្គការ លីកាដូ ខែមករា ឆ្នាំ២០០២ ដែលមានចំណងជើងថា៖ របាយការណ៍អង្គការ លីកាដូ ខែមករា ឆ្នាំ២០០២ ដែលមានចំណងជើងថា៖ Abuses Related to the International Adoption Process in Cambodia, https://www.licadho-cambodia.org/reports/files/31AdoptBPaper.pd

[៦] របាយការណ៍ពីក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២ មានចំណងជើងថា៖ Adoption Processing in Cambodia, https://www.uscis.gov/sites/default/files/files/pressrelease/AdopProcCambodia_020702.pdf.



កុមារនៅក្នុងមជ្ឈមណ្ឌកុមារកំព្រា ដែលត្រូវបានស៊ើបអង្កេតដោយមន្រ្តីរបស់សហរដ្ឋអាមេរិកកាលពីឆ្នាំ ២០០៣ (រូបភាពទទួលបានពីការិយាល័យអន្តោប្រវេសន៍ និងសញ្ញាតូបនីយកម្មរបស់សហរដ្ឋអាមេរិក)

របស់ពលរដ្ឋអាមេរិក ទាក់ទងនឹង ស្មុំកូនដោយក្លែងបន្លំ ដើម្បី យកកុមារទៅចិញ្ចឹមនៅសហរដ្ឋអាមេរិក។ ការស៊ើបអង្កេតនោះ បានឈានឲ្យមានការចោទប្រកាន់ និងចាប់ខ្លួនអ្នកសម្របសម្រួលសកម្មភាពស្មុំកូន ឈ្មោះ Lauryn Galindo និង Lynn Devin ដាក់ពន្ធនាគារនៅ សហរដ្ឋអាមេរិក ពីបទក្លែងទិដ្ឋាការ និងការសំអាតប្រាក់[៧]។ Galindo និង Devin ត្រូវបានអាជ្ញាធររកឃើញថា បានកុហកអាជ្ញាធរអន្តោប្រវេសន៍ ដើម្បីទទួលបាន ទិដ្ឋាការឲ្យកុមារ ដែលនឹងត្រូវនាំយកទៅចិញ្ចឹមដោយ ម្ដាយឪពុកជនជាតិអាមេរិក-កាំង។ អ្នកទាំងពីរ ត្រូវបាន ចោទថាបានអះអាងដោយមិនត្រឹមត្រូវថាកុមារ ត្រូវបានម្ដា យឪពុកបង្កើត បោះបង់ និងមិនស្គាល់ អត្តសញ្ញាណ ម្ដាយឪពុកបង្កើត របស់កុមារ។ នៅក្នុងអំឡុងពេលចោទប្រកាន់ព្រហ្មទណ្ឌ ភ័ស្តុតាងបានបង្ហាញថា Galindo បានប្រគល់ប្រាក់រាប់ពាន់ដុល្លារ ទៅឲ្យមន្ត្រីរាជរដ្ឋាភិបាល សម្រាប់សកម្មភាព ស្មុំកូនម្នាក់ៗ ដែលនាងបានសម្រប សម្រួល។ Galindo និង Devin បានសារភាពកំហុសថា បានសម្របសម្រួល សកម្មភាពស្មុំកូនចំនួន ១៧ករណី ក៏ប៉ុន្តែ អ្នកទាំងពីរ ត្រូវបានរកឃើញថា បានសម្របសម្រួល សកម្មភាពស្មុំកូន ប្រមាណ ៧០០ករណី ពីប្រទេសកម្ពុជា ទៅកាន់សហរដ្ឋអាមេរិក នៅចន្លោះពីឆ្នាំ១៩៩៧ និង២០០១។[៨]

នៅខែមេសា ឆ្នាំ២០០៣ ស្ថានទូតប្រទេសហូឡង់ប្រចាំប្រទេសថៃ បានពិនិត្យឡើងវិញនូវសកម្មភាពស្មុំកូនអន្តរប្រទេសនៅប្រទេសកម្ពុជា។ បន្ទាប់មករបាយការណ៍មួយ[៩] ត្រូវបានចេញដោយបាន ប្រៀបធៀបនីតិវិធីផ្លូវការសម្រាប់ការសុំកូនអន្តរប្រទេស ជាមួយនឹងតថភាពពិតនូវ អ្វី ដែលបានកើតឡើងជាក់ស្ដែង នៅលើករណីភាគច្រើន។ របាយការណ៍នេះ បានរកឃើញថា ចំណុចខ្សោយក្នុងដំណើរការនេះ គឺចំនុចនៃការទទួលយកកុមារមកចិញ្ចឹមនៅមណ្ឌលកុមារកំព្រា ដោយអាជ្ញាធរមូលដ្ឋានបានធ្វើ សំបុត្រកំណើតក្លែងក្លាយ និងឯកសារមិនពិត

[៧] គ្មានបទចោទឧក្រិដ្ឋនោះទេនៅសហរដ្ឋអាមេរិក ករណីការជួញដូរមនុស្សសម្រាប់ការស្មុំកូន
[៨] ការបង្ហាញផ្តល់ដោយ by Richard Cross, US Federal Special Agent ICE, http://fleasbiting.blogspot.com/2015/07/us-ice-agent-what-really-happened-in.html
[៩] របាយការណ៍ពីស្ថានទូតប្រទេសហូឡង់ប្រចាំទីក្រុងបាងកក ខែឧសភា ឆ្នាំ២០០៣ មានចំណងជើងថា៖ , International Child Adoption in Cambodia, A Situation Report (Dutch Report).

បញ្ជាក់ថា កុមារត្រូវបាន ម្តាយឪពុកបង្កើតបោះបង់ចោល ដើម្បីជាថ្នូរនឹងប្រាក់ មួយចំនួនតូច។ ផ្អែកតាមកិច្ចសម្ភាសន៍ ជាមួយម្តាយឪពុកចិញ្ចឹម បានបង្ហាញ ពីអត្រាតម្លៃផ្សេងៗជាច្រើន នៅក្នុងដំណើរការសុំកូននៅកម្ពុជា និងបានរកឃើញថា មានការចំណាយក្រៅផ្លូវការ កើតមានឡើង នៅក្នុងដំណើរការសុំកូន។ របាយការណ៍បានបង្ហាញថា មានការបង់ប្រាក់ ចន្លោះពី២,០០០ ទៅ៤,០០០ ដុល្លារសហរដ្ឋអាមេរិកជូនក្រសួងការបរទេស៥០០ដុល្លារសហរដ្ឋ អាមេរិក ជូនក្រសួងសង្គមកិច្ច និងច្រើនរយដុល្លារជូនទីស្តីការគណៈរដ្ឋមន្ត្រី។ ហើយរបាយការណ៍ ក៏បានបញ្ជាក់ថា ក៏មានការផ្តល់ប្រាក់ចំនួនពី ៨០០ ទៅ ៣,០០០ ដុល្លារសហរដ្ឋអាមេរិក ជូនទៅមណ្ឌលកុមារកំព្រា។[១០]

របាយការណ៍នេះ បានសន្និដ្ឋានថា សុំកូនអន្តរប្រទេសនៅប្រទេសកម្ពុជា "គឺនៅតែជាប់ជំពាក់យ៉ាងជ្រៅជាមួយនឹងសកម្មភាពខុសច្បាប់ និងអំពើដែលត្រូវបានគេអះអាងថា ជាអំពើពុករលួយ ជាច្រើន ហើយនិងកង្វះខាតតម្លាភាព ជាទូទៅ"។ របាយការណ៍ បានបន្តបញ្ជាក់ទៀតថា ដំណើរការសុំកូន មានជាប់ពាក់ព័ន្ធ នឹងចំនួនលុយ ដ៏ច្រើនសន្ធឹកសន្ធាប់ ដែលអាចក្លាយជាសកម្មភាព ទិញលក់កុមារ និង ការជួញដូរមនុស្ស។ ពាក់ព័ន្ធនឹងក្របខណ្ឌគតិយុត្តិ របាយការណ៍ បានបញ្ជាក់ថាស្ថានភាពនៃនីតិវិធីច្បាប់ និងភ្នាក់ងារអនុវត្តច្បាប់ មិនអាចផ្តល់នូវការការពារចាំបាច់ ដើម្បីធានាការអនុវត្ត សុំកូនអន្តរប្រទេសនៅក្នុងលក្ខណៈ ដែលអាចការពារផលប្រយោជន៍របស់កុមារ ម្តាយឪពុកបង្កើត ឬ អនាគតម្តាយឪពុកចិញ្ចឹម បាននោះទេ។[១១]




កូនសៀវភៅព័ត៌មាន ដែលផ្តល់ដោយមន្ត្រីក្រសួងសង្គមកិច្ច មកអង្គការលីកាដូ កាលពីខែមីនា ឆ្នាំ២០១៧

ជាលទ្ធផល នៃការរកឃើញនៅក្នុងការត្រួតពិនិត្យឡើងវិញនេះ ប្រទេសហូឡង់ បានផ្អាកសុំកូនពីប្រទេសកម្ពុជា នៅខែឧសភា ឆ្នាំ២០០៣។ ប្រទេសដទៃទៀត ក៏បានអនុវត្តដូចគ្នា រួមមាន ប្រទេសអង់គ្លេស បារាំង និងអាឡឺម៉ង់។ ក៏ប៉ុន្តែ ទោះជាមានការរកឃើញការក្លែងបន្លំ និង អំពើដែលត្រូវបានគេអះអាងថា ជាអំពើពុករលួយក្នុងដំណើរការ សុំកូននេះក៏ដោយ ក៏នៅមានប្រទេសជាច្រើនទៀតនៅបន្តសកម្មភាពសុំកូននៅក្នុងទសវត្សរ៍ឆ្នាំ២០០០។ កំឡុងពេលនោះ ចំនួនកុមារច្រើនបំផុត គឺត្រូវបានគេសុំយកទៅចិញ្ចឹមនៅប្រទេសអ៊ីតាលី។[១២]

ជាលទ្ធផល នៃការផ្អាកពីសហរដ្ឋអាមេរិក និងប្រទេសមួយចំនួន នៅឆ្នាំ២០០៧ ប្រទេសកម្ពុជាបានអនុម័ត ទទួលយកអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការសុំកូនអន្តរប្រទេស(The Hague Convention)។[១៣] អនុសញ្ញាក្រុងឡាអេ បរិយាយពីអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ ដែលបញ្ជាក់ថា សុំកូនអន្តរប្រទេស គួរត្រូវបានធ្វើឡើង តែក្នុងករណីដែល ការចិញ្ចឹមបីបាច់កុមារនៅក្នុងប្រទេសមិនអាចធ្វើទៅបាន និងតម្រូវឲ្យអាជ្ញាធររដ្ឋធានាថា សុំកូនអន្តរប្រទេសមិនកើតឡើង ដោយសារការទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុដែលមិនត្រឹមត្រូវណាមួយឡើយ។[១៤] អនុសញ្ញាក្រុងឡាអេ មានចែងពីវិធានការមួយចំនួន ក្នុងគោល

---

១០ ទំព័រទី១០ និង ១១ ក្នុងរបាយការណ៍ខាងលើ

១១ ទំព័រទី១៣ និង ១៤

១២ របាយការណ៍ស្ថិតិនៃចំនួនសុំកូនប្រចាំឆ្នាំនៅកម្ពុជា ពី២០០៥-២០០៩ ក្នុងសន្និសិទទីក្រុងឡាអេស្តីពីច្បាប់អន្តរជាតិឯកជន, https://assets. hcch.net/upload/wop/adop2010pd05_kh.pdf.

១៣ អនុសញ្ញាអន្តរជាតិថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៩៣ ស្តីពីកិច្ចការពារកុមារ និងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស, https://www.hcch.net/en/instruments/conventions/full-text/?cid=69 (Hague Convention on International Adoption).

១៤ មាត្រា២១ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ, ២០ វិច្ឆិកា ១៩៨៩, អង្គការសហប្រជាជាតិ http://www.ohchr.org/EN/ProfessionalInterest/Pages/CRC.aspx (អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ)។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន លើអនុសញ្ញាអន្តរជាតិស្តីសិទ្ធិកុមារ នៅឆ្នាំ១៩៩២។)

បំណាងការពារ និងប្រឆាំងការចាប់នៃការបញ្ជូនកុមារចេញពីប្រទេសកម្ពុជា ដោយលួចលាក់នេះ ការលក់ និងការជួញដូរកុមារ ហើយតម្រូវឲ្យប្រទេស ជាហត្ថលេខីនៃអនុសញ្ញានេះ បង្កើតអាជ្ញាធរកណ្តាល ដើម្បីអនុវត្តកាតព្វកិច្ចរបស់ ប្រទេសនោះ ដូចដែលមានចែងក្នុងអនុសញ្ញា។[១៥] កាលពីឆ្នាំ២០០៩ ប្រទេសកម្ពុជា បានអនុម័តច្បាប់ថ្មីមួយស្តីពី ស្មុំកូនអន្តរប្រទេស[១៦] ដើម្បីឲ្យច្បាប់កម្ពុជា ស្របតាម លក្ខខណ្ឌ តម្រូវដោយអនុសញ្ញាក្រុងឡាអេ។ កាលពីពេលមុន ស្មុំកូនអន្តរប្រទេស ត្រូវបានចែងដោយសង្ខេប នៅក្នុងមាត្រាមួយ ចំនួននៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ[១៧] ហើយនិងត្រូវបានចែងយ៉ាងខ្លីនិងមិនច្បាស់លាស់នៅក្នុងអនុក្រឹត្យ ។[១៨] នៅឆ្នាំ២០០៩ ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស បានផ្តល់អំណាច ដល់ក្រសួងសង្គមកិច្ច ជាអាជ្ញាធរកណ្តាលទទួលខុសត្រូវ លើកិច្ចការស្មុំកូនអន្តរប្រទេស។[១៩] ច្បាប់នេះតម្រូវឲ្យ មន្ទីរសង្គមកិច្ច នៅតាមបណ្តាខេត្ត ខំប្រឹងឲ្យអស់លទ្ធភាព ក្នុងការជួយសម្រួល ឲ្យកុមារបានត្រឡប់ទៅរស់នៅជាមួយម្តាយឪពុកបង្កើតវិញ ហើយប្រសិនបើការធ្វើដូច្នេះមិនអាចទៅរួចទេ គួរប្រគល់កុមារឲ្យគេចិញ្ចឹមនៅក្នុងប្រទេសកម្ពុជា មុនពេលពិចារណា ផ្តល់កុមារទៅឲ្យគេយកទៅចិញ្ចឹម នៅបរទេស។[២០]

នៅក្នុងឆ្នាំដដែល ដែលច្បាប់ថ្មី ត្រូវបានអនុម័ត រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្អាករាល់សកម្មភាពស្មុំកូនទាំងអស់ ពីប្រទេសកម្ពុជា យកទៅចិញ្ចឹមនៅបរទេស។ យោងតាមក្រសួងសង្គមកិច្ចសេចក្តីសម្រេចនេះត្រូវបានធ្វើឡើង ដើម្បីទុកពេលវេលា អនុវត្តនីតិវិធីចាំបាច់ដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិ ទីក្រុងឡាអេ ជាពិសេសកិច្ចការទាក់ទងនឹងស្មុំកូនក្នុងប្រទេស និងកិច្ចការសម្រួបសម្រួល ការជួបជុំក្រុមគ្រួសារ របស់កុមារ ដែលបច្ចុប្បន្នកំពុងរស់នៅក្រោមការថែទាំ របស់មណ្ឌលកុមារកំព្រា ជាមួយម្តាយឪពុកបង្កើតវិញ ។[២១] ការផ្អាកគឺនៅតែបន្ត។

ចាប់តាំងពីឆ្នាំ២០០៩ ក្រសួងសង្គមកិច្ច បានបញ្ជាក់ពី ចេតនារបស់ខ្លួន ក្នុងការដកបម្រាមនេះចេញជាច្រើនលើកច្រើនសារ។ ក្នុងសេចក្តីប្រកាស ជាសាធារណៈមួយចុះថ្ងៃទី២ ខែមិនា ឆ្នាំ២០១៥ ក្រសួងសង្គមកិច្ច[២២] បានបញ្ជាក់ថា ប្រទេសកម្ពុជា នឹងចាប់ផ្តើមបើកឲ្យមានស្មុំកូនអន្តរប្រទេសឡើងវិញ លើកុមារដែលត្រូវការ ការថែទាំពិសេស ក្នុងចំនួនតិចតួច ដោយអនុវត្តតាមនីតិវិធីមួយក្រោយពីបញ្ជាក់ថាលែងមានជម្រើសល្អបំផុតផ្សេងៗទៀតហើយ ដើម្បីចិញ្ចឹមកុមារនៅក្នុងប្រទេ ស ។សេចក្តីប្រកាសក៏បា នអ ញ្ជើ ញភ្នាក់ងារស្មុំកូន នៅតាមប្រទេសជាដៃគូមកដាក់ពាក្យ សុំសិទ្ធិប្រតិបត្តិការ នៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ២០១៦ សារព័ត៌មានបានរាយការណ៍ថា[២៣] មន្ត្រីតំណាង រាជរដ្ឋាភិបាលកម្ពុជា បានទៅទស្សនកិច្ចនៅប្រទេសអេស្ប៉ាញ និងម៉ាល់តា ដើម្បីពិភាក្សា ពីការបើកដំ ណើរ ការឡើងវិ ញ នូវសកម្មភាពស្មុំកូន ជាមួយប្រទេសទាំងនេះ។ ទោះបីជាយ៉ាងណា រហូតមកដ ល់ពេលនេះ អាជ្ញាធរ មិនទាន់បានដកបម្រាមនេះ ចេញនៅឡើយទេ។

---

[១៥] មាត្រា៦ នៃអនុសញ្ញាទីក្រុងឡាអេ ស្តីពីស្មុំកូនអន្តរប្រទេស
[១៦] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩, រាជរដ្ឋាភិបាលកម្ពុជា (ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស)។
[១៧] មាត្រា១០៨ ដល់១១៤, ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ២០ កក្កដា ១៩៨៩, រាជរដ្ឋាភិបាលកម្ពុជា។
[១៨] អនុក្រឹត្យលេខ២៩ ស្តីពីការចិញ្ចឹមទារកកំព្រា ឬកុមារដែលគេយកទៅចិញ្ចឹមនៅបរទេស, រាជរដ្ឋាភិបាលកម្ពុជា, ២ មិនា ២០០១។
[១៩] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស
[២០] ដូចខាងលើ, មាត្រា១៣
[២១] សូមមើលកំណត់ចំណាំលេខ ១៩
[២២] សេចក្តីប្រកាសស្តីពីស្មុំកូនអន្តរប្រទេសនៅកម្ពុជា, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ២ មិនា ២០១៥
[២៣] ព័ត៌មានជាភាសាអង់គ្លេស ពីកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ ដែលមានចំណងជើងថា៖ Gov't to talk adoptions on visits to Spain, Malta, Sen David, http://www.phnompenhpost.com/national/govt-talk-adoptions-visits-spain-malta.

# ករណីសំខាន់ៗដែលត្រូវបានឃ្លាំមើលនៅឆ្នាំ ២០១៧

ករណីចំនួនបី ដែលត្រូវបានឃ្លាំមើល ដោយអង្គការ លីកាដូ មានដូចរៀបរាប់ខាងក្រោម។ ក្នុងករណីនីមួយៗ មានការវិភាគខ្លីមួយអំពីការក្លែងបន្លំ ដែលអង្គការលីកាដូ ជឿជាក់ថា ត្រូវបានប្រព្រឹត្តឡើង និងការវិភាគអំពីចំនុចមួយចំនួននៃច្បាប់ជាតិ និង អន្តរជាតិមួយចំនួន ដែលត្រូវបានរំលោភបំពាន។ ដើម្បីរក្សាអត្តសញ្ញាណអ្នកដែលពាក់ព័ន្ធ ព័ត៌មានមួយចំនួន ត្រូវបានដកចេញ។

## ករណីទី១

ករណីដំបូង បានចាប់ផ្តើមកាលពីឆ្នាំ២០០១ ពេលដែលម្តាយវ័យក្មេង និងជាស្ត្រីមេម៉ាយថ្មីថ្មោងម្នាក់ បានសម្រេចចិត្ត យកទារកអាយុប្រាំបួនខែរបស់នាង ដែលកំពុងឈឺធ្ងន់ ទៅឲ្យមណ្ឌលកុមារកំព្រាមួយ ដែលនៅក្បែររាជធានីភ្នំពេញ ជួយមើលថែរក្សា។ ទារកនោះ ត្រូវការការមើលថែរក្សាឲ្យបានដិតដល់ ដែលម្តាយមិនមានលទ្ធភាពផ្តល់ឲ្យបាន ដោយសារនាងត្រូវធ្វើការប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍ នៅក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់មួយ។ គ្រូពេទ្យធ្លាប់បានប្រាប់នាងថា ប្រសិនបើគ្មានការព្យាបាលនៅបរទេសទេនោះ កូនប្រុសរបស់នាង អាចនឹងស្លាប់។ មណ្ឌលកុមារកំព្រានោះ ដំណើរការ ដោយមូលនិធិសប្បុរសធម៌ របស់ប្រជាពលរដ្ឋសហរដ្ឋអាមេរិកមួយ ហើយទទួលមើលថែរក្សាកុមារ ដែលមានជំងឺមួយចំនួន។ ប្រធានមណ្ឌលកុមារកំព្រា បានប្រាប់នាងថា គាត់នឹងរកវិធីបញ្ជូនកូនប្រុសនាង ទៅក្រៅប្រទេស ដើម្បីទទួលការព្យាបាល ដោយសង្ឃឹមថា កូននាង នឹងអាចជាសះស្បើយ។

**មណ្ឌលកុមារកំព្រា ប្រាប់ម្តាយទារក ថា កូននាងត្រូវទៅសហរដ្ឋអាមេរិក ដើម្បីទទួលការព្យាបាលជំងឺនៅទីនោះ។ នាងមិនត្រូវបានគេប្រាប់ថា ពេលណាកូនរបស់នាងនឹងត្រូវចាកចេញនោះទេ ហើយនាងបានត្រឹមតែដឹងដំណឹងនេះ នៅពេលដែលនាងទៅមើលកូនរបស់នាង នៅថ្ងៃអាទិត្យមួយដូចសព្វដងប៉ុណ្ណោះ។**

ម្តាយបានទៅមើលទារកជារៀងរាល់ថ្ងៃអាទិត្យ ជាថ្ងៃដែលនាងឈប់សម្រាកពីការងារ។ មណ្ឌលកុមារកំព្រាមិនដែលបាន ពិគ្រោះអំពី ភាពជាអាណាព្យាបាលលើកូនជាមួយនាងទេ ឬ ក៏មិនបានស្នើឲ្យនាងចុះហត្ថលេខាលើឯកសារ ណាមួយដែរ។ ពីរបីសប្តាហ៍ ក្រោយមក ប្រធានមណ្ឌលកុមារកំព្រា បានប្រាប់ ឲ្យនាងជាម្តាយដឹងថា ពួកគេ នឹងបញ្ជូនទារកទៅកាន់ទីក្រុងបាងកក ដើម្បីទទួលការព្យាបាល។ ទារកនោះ បានទទួលការព្យាបាលនៅទីនោះរយៈពេលប្រហែលមួយសប្តាហ៍ ហើយបន្ទាប់ពីត្រឡប់មកវិញ ស្ថានភាពរបស់ទារកបាន ប្រសើរឡើង



រូបថតម្តាយ និងកូនប្រុស ថតជាមួយគ្នានៅក្នុងមជ្ឈមណ្ឌលកុមារកំព្រា នៅចន្លោះឆ្នាំ២០០២-០៣

ប៉ុន្តែមិនជាសះស្បើយនោះទេ។ រយៈកាលកន្លង បន្ទាប់ពីនោះ ប្រធានមណ្ឌលកុមារកំព្រា ប្រាប់ម្តាយទារកថា កូននាង ត្រូវទៅសហរដ្ឋអាមេរិក ដើម្បីទទួលការព្យាបាល

ជំងឺនៅទីនោះ។ នាងមិនត្រូវបានគេប្រាប់ថា ពេលណាកូនរបស់នាង នឹងត្រូវចាកចេញនោះទេ ហើយនាងបានត្រឹមតែដឹងដំណឹងនេះ នៅពេលដែលនាង ទៅមើលកូនរបស់នាង នៅថ្ងៃអាទិត្យមួយដូចសព្វដងប៉ុណ្ណោះ។ នាងក៏មិនត្រូវបានគេ ស្នើឲ្យចុះហត្ថលេខាយល់ព្រម លើលិខិតស្នាមណាមួយ ទាក់ទងនឹងការបញ្ជូន កូននាងទៅសហរដ្ឋអាមេរិកនោះឡើយ។

បន្ទាប់ពីទារកនោះបានចេញទៅម្តាយបានបន្តទៅមណ្ឌលកុមារកំព្រា ប្រហែលមួយខែម្តង ដើម្បីសួរពីដំណឹងកូនប្រុសរបស់នាង។ ប្រធានមណ្ឌល ធ្លាប់ប្រាប់នាងថា កូននាងមិនអីទេ ហើយប្រាប់ថា កុំឲ្យបារម្ភ។ ពេលវេលាជាច្រើនឆ្នាំ បានកន្លងផុតទៅ ហើយនាងនៅតែបន្តទូរស័ព្ទទៅមណ្ឌលកុមារកំព្រា ប៉ុន្តែមិនបានដំណឹងអ្វីសោះឡើយ។ កាលពីឆ្នាំ២០០៥ បុគ្គលិកមណ្ឌលកុមារកំព្រាម្នាក់ បានទៅផ្ទះរបស់នាង ហើយស្នើនាងឲ្យចុះហត្ថ-លេខា លើឯកសារចំនួនពីរច្បាប់ ហើយនាងក៏បានយល់ព្រម។ នាងអាចអានអក្សរបាន ប៉ុន្តែអានមិនស្ទាត់ទេ ហើយនាងបានឃើញឯកសារមួយ បញ្ជាក់ពីការយល់ព្រម ឲ្យគេបញ្ជូនកូនប្រុសនាងទៅបរទេស ដើម្បីព្យាបាលជំងឺ។ នាងបានគិតថា ឯកសារមួយទៀត ក៏ប្រហែលមានខ្លឹមសារដូចគ្នាដែរ។ បុគ្គលិកនោះ ក៏បានប្រគល់ឲ្យនាងនូវសំបុត្រកំណើតរបស់កូន។ កាលបរិច្ឆេទលើសំបុត្រកំណើតនោះ គឺត្រូវបានគេប្តូរ ដោយខុសគ្នា មួយខែ ហើយឈ្មោះរបស់កូនក៏ខុសទៀត។ កូននាងត្រូវបានគេដាក់ឈ្មោះឲ្យថា "រដ្ឋ" ដែលមានន័យថារដ្ឋ ឬរដ្ឋាភិបាល។ ឈ្មោះបែបនេះ ត្រូវបានគេផ្តល់ឲ្យ កុមារដែលគេមិនស្គាល់ពីអត្តសញ្ញាណ របស់ម្តាយឪពុកកុមារ ហើយវាតែងតែ ត្រូវបានគេប្រើ លើសំបុត្រកំណើតក្លែងក្លាយ និងលិខិតស្នាមដទៃទៀត ដើម្បីងាយស្រួល ដំណើរការស្មុំកូន ដែលមានម្តាយឪពុកបង្កើត នៅរស់នៅឡើយ។ សំបុត្រកំណើតត្រូវបាន ចុះហត្ថលេខាដោយមេឃុំនៅទីតាំង ដែលមណ្ឌលកុមារកំព្រា តាំងនៅ។

ជាច្រើនឆ្នាំក្រោយមក ស្ត្រីជាម្តាយនៅតែព្យាយាមទាក់ទងទៅមណ្ឌលកុមារកំព្រា ប៉ុន្តែអ្នកទាំងនោះមិនបានផ្តល់ព័ត៌មានអ្វីឲ្យនាងនោះឡើយ។ នាងបានព្យាយាមប្រើប្រាស់មធ្យោបាយផ្សេងទៀត ដើម្បីស្វែងរកកូនប្រុសនាង ប៉ុន្តែមិនទទួលបានជោគជ័យនោះទេ។

ការឃ្លាំមើលរបស់ អង្គការលីកាដូ បានបង្ហាញថា ពេលដែលទារកនោះទៅសហរដ្ឋអាមេរិក វាត្រូវបានគេដាក់ក្រោមការមើលថែរក្សា ជាបណ្តោះអាសន្ន ជាមួយគ្រួសារមួយ ខណៈកុមារនោះកំពុងទទួលការព្យាបាលជំងឺ។ ប្រសិនបើគ្មានឯកសារគ្រប់គ្រាន់នោះ នឹងមានការលំបាក ក្នុងការប្រមូលផ្តុំព័ត៌មានចូលគ្នា ដើម្បីឲ្យអាចយល់បានថា អ្វីខ្លះបាន កើតឡើងឲ្យពិតប្រាកដ ក៏ប៉ុន្តែទំនងជាគ្រួសារនោះក្រោយមក បានទទួលយកទារកនោះទៅចិញ្ចឹម។

ដោយសារតែម្តាយមិនដែលបានចុះហត្ថលេខាលើឯកសារណាមួយ ទាក់ទងនឹងកូនប្រុសនាង ឬទាក់ទងនឹងការធ្វើដំណើររបស់កូនប្រុសនោះទៅបរទេស នេះទំនងជាអាចមាននរណាម្នាក់នៅឯមណ្ឌលកុមារកំព្រា បន្លំខ្លួនធ្វើជាអាណាព្យាបាលតាមផ្លូវច្បាប់របស់កុមារ នៅក្នុងទម្រង់បែបបទស្នើសុំទិដ្ឋាការ ឬកំឡុងពេលដំណើរការស្មុំកូនក្រោយមក នៅសហរដ្ឋអាមេរិក។ ការទៅជួបស្ត្រីជាម្តាយកាលពីឆ្នាំ២០០៥ របស់បុគ្គលិកមណ្ឌល និងការបង្កើតសំបុត្រកំណើត ហាក់ដូចជាផ្នែកមួយនៃការប៉ុនប៉ងបង្កើតឯកសារ ដើម្បីឲ្យការទៅសហរដ្ឋអាមេរិកមានភាពស្របច្បាប់ និងដើម្បីបញ្ជាក់ថាទារកនោះ ត្រូវបានម្តាយឪពុកបោះបង់ចោល ហើយដែលហេតុដូច្នេះហើយបានជាកុមារនោះ អាចត្រូវបានគេប្រគល់ឲ្យអ្នកដទៃយកទៅចិញ្ចឹមបាន។

សកម្មភាពស្មុំកូននេះ ល្មើសនឹងបម្រាមរបស់សហរដ្ឋអាមេរិក នៅឆ្នាំ២០០១ ប៉ុន្តែដោយសារកុមារធ្វើដំណើរទៅសហរដ្ឋអាមេរិក គឺដើម្បីព្យាបាលជំងឺ ករណីនេះបានរួចផុតពីសេចក្តីបម្រាម ដែលបានដាក់ចេញ។ ឯកសារមួយចំនួន ដែលត្រូវពិនិត្យឡើងវិញក្នុងពេលឃ្លាំមើល បានបង្ហាញថា ជានិច្ចកាល នេះគឺជាចេតនារបស់មណ្ឌលកុមារកំព្រា ដែលចង់ឲ្យ កុមារត្រូវបានគេយកទៅចិញ្ចឹមនៅក្នុងសហរដ្ឋអាមេរិក។ កុមារដទៃក៏អាចត្រូវបានគេយកចេញពីមណ្ឌលកុមារកំព្រាតែមួយ ទៅចិញ្ចឹមនៅសហរដ្ឋអាមេរិក តាមវិធីដូចគ្នានេះ។ មណ្ឌលកុមារកំព្រានេះ ត្រូវបានគ្រប់គ្រងមួយផ្នែកដោយអតីតសហការីរបស់អ្នកស្រី Lauryn Galindo ដែលជាអ្នកសម្របសម្រួលសកម្មភាពស្មុំកូន និងដែលត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ នៅសហរដ្ឋអាមេរិក ពីបទល្មើសជាប់ទាក់ទងនឹងដំណើរការស្មុំកូនក្លែងបន្លំនៅកម្ពុជា។

## ករណីទី២

នៅឆ្នាំ២០០៥ ម្តាយម្នាក់ដែលមានកូនប្រាំនាក់ និងស្វាមី ដែលបានធ្លាក់ខ្លួនឈឺជាទម្ងន់ បានយកកូនចំនួនបួននាក់ទៅដាក់នៅមណ្ឌលកុមារកំព្រា នៅរាជធានីភ្នំពេញ ដើម្បីឲ្យពួកគេបានទៅសាលារៀន។ មុនពេលប្តីនាងមានជំងឺ គ្រួសារនេះ បានរស់នៅជួបជុំគ្នានៅខេត្តមួយភាគខាងត្បូងប្រទេសកម្ពុជា។ គ្រួសារនេះក្រីក្រ ប៉ុន្តែពួកគេអាចរស់បានដោយសារស្វាមីរបស់នាងមានមុខរបរជាអ្នករត់ម៉ូតូឌុប ហើយនាងប្រកបរបរចិញ្ចឹមសត្វ និងដាំបន្លែបន្តិចបន្តួច។ បន្ទាប់ពីស្វាមីនាងធ្លាក់ខ្លួនឈឺខ្លាំង ដែលមិនអាចធ្វើការបាន នាងបានសម្រេចចិត្តមកភ្នំពេញ ដើម្បីធ្វើការនៅក្នុងរោងចក្រកាត់ដេរ។ នាងបានជួលបន្ទប់មួយដើម្បីរស់នៅជាមួយកូនៗ ហើយដោយសារតែនាង មិនមានលទ្ធភាពបញ្ជូនកូនទៅសាលារៀន កូនៗរបស់នាងត្រូវនៅផ្ទះពេញមួយថ្ងៃ។ ម្ចាស់ផ្ទះរបស់នាង បានរអ៊ូរទាំរឿងនេះ ដូច្នេះនាងបានរើចេញ និងបានដើររកជួលបន្ទប់នៅថ្មី។ កូនៗនាងបានប្រាប់នាងថា ពួកគេចង់ទៅរៀន ហេតុនេះហើយទើបនាង បានសម្រេចចិត្តដើររកកន្លែងស្នាក់នៅ ដែលអាចផ្តល់ការរៀនសូត្រ ដល់កូនៗរបស់នាងបាន។ [២៤]

អ្នកជិតខាងម្នាក់ បានប្រាប់នាង ពីមណ្ឌលកុមារកំព្រាមួយ ដែលអ្នកជិតខាងនោះធ្លាប់បានបញ្ជូនកូនស្រីរបស់ខ្លួនទៅទីនោះ។ នាងបានយកកូនរបស់នាង ទៅមណ្ឌលនោះ ហើយបានជួបប្រធានមណ្ឌល ដែលបន្ទាប់មកបានយល់ព្រមទទួលកូននាង និងបញ្ជូនពួកគេទៅសាលារៀន។ ប្រធានមណ្ឌល បានរៀបចំឯកសារចំនួនពីរច្បាប់ ដើម្បីបញ្ជាក់ពីការទទួលកុមារនេះ ហើយប្រគល់ឯកសារនេះមួយច្បាប់ទៅនាងជាម្តាយ។ ឯកសារនោះមិនបាននិយាយអ្វីពាក់ព័ន្ធនឹងសកម្មភាពសុំកូននោះទេ។

**ត្រង់ចំណុចមួយចំនួននៃករណីនេះ សំបុត្រកំណើតក្លែងក្លាយត្រូវបានបង្កើតឡើង ដែលមានដាក់ថ្ងៃខែឆ្នាំកំណើតខុស និងមិនមានឈ្មោះម្តាយឪពុកបង្កើតរបស់កុមារ។ នេះជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិកុមារស្តីពីអត្តសញ្ញាណ។ នេះមិនត្រឹមតែធ្វើឲ្យកុមារ យល់ថាពួកគេក្មេងជាងអាយុពិតប៉ុណ្ណោះទេ ហើយថែមទាំងធ្វើឲ្យមានការលំបាកសម្រាប់កុមារក្នុងការស្វែងរក ម្តាយឪពុកបង្កើតរបស់កុមារ ប្រសិនបើពួកគេចង់ស្វែងរក។**



ម្តាយ និងជីតារបស់កុមារពីរនាក់ ដែលត្រូវបានគេយកទៅចិញ្ចឹមនៅប្រទេសអូទ្រីស កំពុងមើលរូបថតគ្រួសារចាស់ៗ ខែមករា ឆ្នាំ២០១៨

[២៤] យោងតាមច្បាប់ ការរៀននៅសាលារដ្ឋ មិនតម្រូវឲ្យបង់ប្រាក់នោះទេ នៅប្រទេសកម្ពុជា ប៉ុន្តែសិស្សស្ទើរគ្រប់គ្នា តម្រូវឲ្យបង់ប្រាក់ក្រៅផ្លូវការជូនទៅគ្រូបង្រៀន ប្រសិនបើពួកគេចង់ចូលសាលារៀន។

ពីដំបូង នាងបានទៅមើលកូនជារៀងរាល់ថ្ងៃអាទិត្យ ដែលជាពេលនាងឈប់សម្រាកពីការងារ ប៉ុន្តែប្រពន្ធរបស់ប្រធានមណ្ឌលបានប្រាប់នាងថា នាងមិនគួរទៅសួរសុខទុក្ខញឹកញាប់ពេកទេ ដូច្នេះម្ដាយបានកាត់បន្ថយការទៅសួរសុខទុក្ខកូន មកត្រឹមពីរអាទិត្យម្ដង។ ឪពុកជរារបស់នាងនេះ ក៏ទៅសួរសុខទុក្ខកុមារនោះដែរ។ ពីរបីខែក្រោយបន្ទាប់ពី កូនៗផ្លាស់ទៅនៅមណ្ឌលនោះ នាងបានឮដំណឹងពីកូនម្នាក់របស់នាងថា មានប្ដីប្រពន្ធបរទេសមួយគូរទៅមណ្ឌល និងបានយកកូនស្រីម្នាក់របស់នាងចេញទៅ ។ នាងបានជជីកសួរប្រធានមណ្ឌល ថាហេតុអ្វីបានគាត់ធ្វើដូច្នេះ។ គាត់បានឆ្លើយតបថា ប្រសិននាងបានដឹងពីរឿងនេះ និងបានឃើញ ជនបរទេសយកកូនស្រីនាងចេញទៅ នាងនឹងដួលសន្លប់ ដោយភាពតក់ស្លុតជា មិនខាន ហេតុនេះនាងមិនគួរដឹងពីរឿងនេះទេ។ ប្រធានមណ្ឌលនោះ ក៏បាននិយាយទៀតថា ដោយសារតែ នាងក្រីក្រពេក ការបញ្ជូនកូនស្រីនាងឲ្យទៅរស់នៅឆ្ងាយ គឺជាការផ្ដល់ឱកាសល្អមួយដល់កូនស្រីនាង ដើម្បីឲ្យកុមារនោះមានអនាគតល្អ។ ប្រធានមណ្ឌលនោះ បានប្រាប់នាងថា ខាងមណ្ឌលនឹងរក្សាទំនាក់ទំនង ជាមួយគ្រួសារជាម្ដាយឪពុកចិញ្ចឹម ហើយថាក្រុមគ្រួសារថ្មីនោះ នឹងផ្ដល់ដំណឹង និងរូបថតមកមណ្ឌលជាទៀងទាត់។ នាងបានសុំអាស័យដ្ឋានថ្មីរបស់កូនស្រីនាង ពីប្រធានមណ្ឌល ហើយគាត់បានឆ្លើយតបថា គាត់នឹងឲ្យនាង ពេលដែលក្រុមគ្រួសារថ្មីនោះ ផ្ញើមក។ នាងបានប្រាប់ប្រធានមណ្ឌលថា នាងចង់យកកូន ដែលនៅសល់ទាំងអស់ត្រឡប់ទៅផ្ទះវិញ។ គាត់បានឆ្លើយថា នាងមិនអាចយកពួកគេទៅវិញតាមដែលចិត្តនាងចង់នោះទេ ពីព្រោះឈ្មោះកូនៗទាំងនោះ ត្រូវបានចុះបញ្ជីនៅក្រសួងសង្គមកិច្ចរួចទៅហើយ។ នាងមិនយល់ពីអ្វី ដែលប្រធានមណ្ឌលនោះប្រាប់នាងនោះទេ។ប៉ុន្មានសប្ដាហ៍ក្រោយមក នាងបានឮពីកូនប្រុសនាងថា មានស្ត្រីបរទេសម្នាក់ បានមកមណ្ឌលកុមារកំព្រា ហើយ បានយកប្អូនប្រុសចេញទៅ។ ពេលដែលនាងនៅកន្លែងធ្វើការ ឪពុកនាងបានទៅមណ្ឌលកុមារកំព្រាហើយ បាននិយាយជាមួយប្រធានមណ្ឌល ដោយសុំកុំឲ្យគេយកចៅរបស់គាត់ចេញទៅ។ ប្រធានមណ្ឌលបានប្រាប់គាត់ថា យឺតពេលហើយ ដោយសារតែរាល់ឯកសារផ្លូវការ ដែលត្រូវចេញ ពីក្រសួងសង្គមកិច្ចទាំងប៉ុន្មាន ត្រូវបានរៀបចំរួចរាល់អស់ហើយ។ កុមារានោះ ត្រូវបានគេនាំយកចេញទៅ នៅថ្ងៃតែមួយនោះ ដោយមិនបានជួបម្ដាយជាលើកចុងក្រោយនោះទេ។

សប្ដាហ៍បន្ទាប់មកទៀត ជីតារបស់កុមារ បានទៅក្រសួងសង្គមកិច្ច និងបានទៅសួរមន្ត្រីនៅទីនោះ ពីកន្លែងដែលចៅគាត់បានចេញទៅ ហើយបាននិយាយថាគាត់ចង់បានចៅរបស់គាត់មកវិញ។ មន្ត្រីនៅទីនោះ បានប្រាប់គាត់ថា កុមារទាំងនោះ បានទៅប្រទេសអូទ្រីសហើយ ហើយថា យឺតពេលហើយ ដែលចង់យកក្មេងទាំងនោះត្រឡប់មកវិញនោះ។ ភ្លាមៗបន្ទាប់ពីនោះមក ប្រធានមណ្ឌល បានប្រាប់ស្ត្រីជាម្ដាយនោះថា នឹងមានគម្រោងបញ្ជូន កូនដែលនៅសល់ផ្សេងទៀតរបស់នាង ទៅប្រទេសបារាំង ប៉ុន្តែដោយសារឪពុករបស់នាង បានប្ដឹងទៅក្រសួងសង្គមកិច្ច ដូចនេះកូនដែលនៅសល់របស់នាង នឹងមិនត្រូវបានគេនាំយកទៅចិញ្ចឹមនៅ ក្រៅ ប្រទេស ទៀតទេ ហើយ នឹងត្រូវបន្តស្នាក់នៅក្នុងមណ្ឌលកុមារកំព្រា រហូតដល់ក្មេងទាំងនោះរៀនចប់។

ស្ត្រីជាម្ដាយរបស់កុមារទាំងនោះ តែងទៅលេងកូនៗ ដែលនៅសល់នៅក្នុងមណ្ឌលកុមារកំព្រា ហើយជារឿយៗ តែងតែសួរប្រធាន មណ្ឌល អំពីព័ត៌មានកូនទាំងពីររបស់នាង ដែលត្រូវ បា នគេនាំចេញទៅបរទេស។ មួយរយៈក្រោយមក ប្រធានមណ្ឌល បានឲ្យនាងនូវរូបថតមួយចំនួនរបស់កុមារទាំងពីរ ដែលបានថតជាមួយគ្រួសារចិញ្ចឹមរបស់ពួកគេ ក៏ប៉ុន្តែ នាងមិនបានទទួល អ្វីក្រៅពីនេះទៀតទេ។

ក្រោយពេល កូនទាំងពីរ បានចាកចេញពីមណ្ឌលកុមារកំព្រា នៅឆ្នាំ២០១៤ ម្ដាយ បានសរសេរលិខិតមួយដាក់ជូនរដ្ឋសភាកម្ពុជា ដើម្បីស្នើសុំព័ត៌មានអំពីកូនរបស់នាងដែលគេយកចេញទៅបរទេស។ នាង បានទទួលការឆ្លើយតបពីក្រសួងសង្គមកិច្ច ដែលបានបញ្ជាក់ថា កូនទាំងពីរនោះ គឺកំពុងរស់នៅក្នុងប្រទេសអូទ្រីស ប៉ុន្តែគេមិនអាចផ្ដល់អាស័យដ្ឋានកូនៗនាងនៅទីនោះ មកឲ្យនាងបាននោះទេ ព្រោះដោយយោងតាមច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ការយកកូនៗនាងទៅចិញ្ចឹម គឺជាសុំកូនពេញលេញ មានន័យថា នឹងមិនមានទំនាក់ទំនងរវាងម្ដាយបង្កើត និងកូនៗនាងតទៅទៀតនោះទេ។ នៅក្នុងលិខិតនោះ ក្រសួងសង្គមកិច្ចបានផ្ដល់ឈ្មោះកូននោះថា “រដ្ឋ” ហើយថ្ងៃខែឆ្នាំកំណើតរបស់កូននោះ គឺខុស ដែលនៅក្នុងនោះបង្ហាញថាអាយុរបស់កុមារ ក្មេងជាងអាយុពិត ចំនួនពីរឆ្នាំ។ ភស្តុតាងនេះ បញ្ជាក់ថា សំបុត្រកំណើតក្លែងក្លាយ និងលិខិតបោះបង់កូនក្លែងក្លាយ គឺត្រូវបានគេបង្កើតឡើង ដើម្បីឲ្យកុមារទាំងពីរ អាចត្រូវបានគេយកទៅចិញ្ចឹម។

កាលពីឆ្នាំ២០០៦ នៅពេលដែលសកម្មភាពសុំកូននេះបានកើតឡើង សកម្មភាពសុំកូនក្នុងស្រុក និងអន្តរប្រទេសនៅ កម្ពុជា ត្រូវបានអនុវត្ត ទៅតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលបានតម្រូវថា ដើម្បីឲ្យដំណើរការសុំកូន អាចបន្តទៅមុខបាន កុមារម្នាក់ត្រូវតែជាកុមារដែលត្រូវបាន ម្តាយឪពុកបង្កើតបោះបង់ចោល ឬក៏ម្តាយឪពុករបស់កុមារ ផ្តល់ការយល់ព្រមឲ្យមានការយកកូនរបស់ខ្លួន ទៅចិញ្ចឹម។ ប៉ុន្តែក្នុងករណីនេះ មិនត្រឹមតែប្រធានមណ្ឌល កុមារកំព្រានោះទេ មន្ត្រីក្រសួងសង្គមកិច្ចក៏បានដឹង យ៉ាងច្បាស់ដែរថា កុមារទាំងនោះ មិនមែនត្រូវបានម្តាយឪពុកបង្កើតបោះបង់ចោល នោះឡើយ ហើយដឹងច្បាស់ដែរថា ម្តាយឪពុកបង្កើតនឹង បដិសេធការសុំកូនរបស់ខ្លួនទៅចិញ្ចឹម ក៏ប៉ុន្តែសកម្មភាពសុំកូន នៅតែត្រូវបានគេធ្វើឡើង។

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័ន ទទួលយកអនុសញ្ញា អន្តរជាតិស្តីពី សិទ្ធិកុមារ នៅឆ្នាំ១៩៩២។ អនុសញ្ញានេះ តម្រូវថា សកម្មភាពសុំកូន ត្រូវតែធ្វើឡើងឲ្យស្របតាមច្បាប់ជាធរមាន ដែលសុំកូន អាចប្រព្រឹត្តិទៅបាន ដោយត្រូវពិនិត្យមើល ពីទំនាក់ទំនងរបស់កុមារជាមួយម្តាយឪពុករបស់កុមារនោះហើយម្តាយឪពុកបង្កើតត្រូវផ្តល់ការយល់ព្រម ដែលកើតចេញពីការដឹងលឺពីសកម្មភាពសុំកូននោះ។[២៥]

ដូចដែលបានបញ្ជាក់ពីខាងលើ ច្បាប់កម្ពុជា ជាធរមានមិនត្រូវបានគេអនុវត្តឲ្យបានខ្ជាប់ខ្ជួននោះទេ ទំនាក់ទំនងរវាងម្តាយបង្កើត និងកុមារនៅតែបន្តមាន នៅពេលមានសកម្មភាព សុំកូនកើតឡើង ហើយម្តាយបង្កើតនោះទៀតសោត ក៏មិនបានផ្តល់ការយល់ព្រមលើ សកម្មភាពសុំកូននេះដែរ។ អនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារក៏បានតម្រូវឲ្យអាជ្ញាធររដ្ឋ ការពារសិទ្ធិរបស់កុមារ ដើម្បីរក្សាអត្តសញ្ញាណ រួមមានឈ្មោះ និងសញ្ជាតិ ដោយមិនមានការជ្រៀតជ្រែកដោយខុសច្បាប់។[២៦] ត្រង់ចំណុចមួយចំនួននៃករណីនេះ សំបុត្រកំណើតក្លែងក្លាយត្រូវបានបង្កើតឡើង ដែលមានដាក់ ថ្ងៃខែឆ្នាំកំណើតខុស និងមិនមានឈ្មោះម្តាយឪពុកបង្កើតរបស់កុមារ ។ នេះជាការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើសិទ្ធិកុមារស្តីពីអត្តសញ្ញាណ។ នេះមិនត្រឹមតែធ្វើឲ្យកុមារយល់ថា ពួកគេក្មេងជាងអាយុពិតប៉ុណ្ណោះទេ ហើយថែមទាំងធ្វើឲ្យ មានការលំបាកសម្រាប់កុមារ ក្នុងស្វែងរកម្តាយឪពុកបង្កើត របស់កុមារប្រសិនបើពួកគេចង់ស្វែងរក។

ការពឹងផ្អែករបស់ក្រសួងសង្គមកិច្ចលើច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩ ដើម្បីអះអាងថា សកម្មភាពសុំកូននោះ គឺជាសុំកូនពេញលេញ និងអះអាងថា ហេតុដូច្នេះ ហើយទើបមន្ត្រីទាំងនោះ មិនអាចផ្តល់ព័ត៌មានណាមួយជូនម្តាយបង្កើតនោះ គឺមិនត្រឹមត្រូវនោះទេ។ ច្បាប់នោះ ពិតជាបានបញ្ជាក់ថា រាល់សកម្មភាពសុំកូនអន្តរប្រទេសទាំងអស់ ត្រូវជាសកម្មភាពសុំពេញលេញ ហើយរាល់ទំនាក់ទំនងរវាងកូន និងម្តាយឪពុកបង្កើត គឺត្រូវបញ្ចប់នៅពេលសុំកូន ។[២៧] ក៏ប៉ុន្តែច្បាប់នេះ មិនទាន់ត្រូវបានគេយកមកអនុវត្ត នៅឆ្នាំ២០០៦ នោះទេ នៅពេលដែលសកម្មភាពសុំកូនទាំងនោះ បានកើតឡើង។ ច្បាប់ដែលអាចត្រូវបានគេអនុវត្តនៅពេលនោះ មិនបានផ្តល់ព័ត៌មានលម្អិតណាមួយ អំពីលក្ខណៈ នៃសកម្មភាពសុំកូននោះដែរ។[២៨] លើសពីនេះទៅទៀត នៅក្នុងករណីនេះដោយ ផ្អែកលើការរំលោភបំពានលើលក្ខខណ្ឌច្បាប់ ដែលតម្រូវឲ្យមានការយល់ព្រម ពីម្តាយឬឪពុកបង្កើត ដើម្បីឲ្យមានសកម្មភាពសុំកូនកើតឡើង ការសំអាងលើការ អនុវត្តខ្ជាប់ខ្ជួន របស់ក្រសួងសង្គមកិច្ច លើមាត្រានៅក្នុងច្បាប់ឆ្នាំ២០០៩ ដែលបានចែងថា រាល់សកម្មភាពសុំកូនអន្តរប្រទេសទាំងអស់ ត្រូវជាអំពើសុំកូនពេញលេញ គឺជាការអនុវត្តស្តង់ដារពីរផ្សេងគ្នារបស់អាជ្ញាធររដ្ឋ ដែលផ្តល់អាទិភាព ដល់សិទ្ធិរបស់ម្តាយឪពុកចិញ្ចឹមបរទេស ច្រើនជាងសិទ្ធិរបស់ភាគីដទៃផ្សេងទៀត។

## ករណីទី៣

ករណីនេះ ជាករណីថ្មីបំផុត ចាប់តាំងពីឆ្នាំ២០០៨។ ប្តីនិងប្រពន្ធមួយគូរ បានរស់នៅ និងធ្វើការនៅក្នុងចំការកៅស៊ូមួយ ដែលមានចម្ងាយមិនឆ្ងាយប៉ុន្មានពីរាជធានីភ្នំពេញ។ ពួកគេ មានកូនចំនួនប្រាំមួយនាក់ ហើយគ្មានលទ្ធភាពបញ្ជូនកូនទៅសាលារៀន ដោយសារ តែក្រីក្រពេក។ អ្នកជិតខាងម្នាក់ បានប្រាប់អ្នកទាំងពីរថា នាងបានបញ្ជូនកូនចំនួនបួននាក់របស់នាង ទៅរស់នៅក្នុងមណ្ឌលកុមារកំព្រាមួយ នៅភ្នំពេញ ដើម្បីឲ្យកូនៗទាំងនោះអាចបានទៅសាលារៀន។ កូនរបស់អ្នកទាំងពីរម្នាក់ បានលឺ ហើយបានប្រាប់ម្តាយនាងថា នាងចង់ទៅរស់នៅឯ

[២៥] មាត្រា២១(ក), អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ
[២៦] ដូចខាងលើ, មាត្រា៨
[២៧] មាត្រា៤១, ច្បាប់ស្តីពីសុំកូនអន្តរប្រទេស
[២៨] ក្នុងប្រទេសកម្ពុជា មិនមានប្រវត្តិនៃសុំកូនពេញលេញនោះទេ។ ខណៈដែលកុមារអាចទៅរស់នៅបណ្តោះអាសន្ន ជាមួយសមាជិកក្រុមគ្រួសារផ្សេងទៀត ឬក៏មិត្តភក្តិ ប្រសិនបើម្តាយឪពុកបង្កើតស្លាប់ ឬក៏ដើម្បីមានឱកាសរៀនសូត្រ ភាពផុតរលត់នៃទំនាក់ទំនងរវាងម្តាយឪពុក និងកូនតាមច្បាប់ គឺកម្រនឹងកើតមានឡើងណាស់។

មណ្ឌលកុមារកំព្រា ដើម្បីបានទៅរៀន ហើយពេលធំឡើង នាងមិនចង់ធ្វើការងារដូចម្ដាយឪពុក នាងទេ។ ស្ត្រីជាម្ដាយ បានសួរទៅអ្នកជិតខាងនោះ ពីលេខទំនាក់ទំនងទៅប្រធានមណ្ឌលកុមារកំព្រា ហើយប្រហែលមួយសប្ដាហ៍ក្រោយ ប្រធានមណ្ឌលនោះ បានធ្វើដំណើរពីភ្នំពេញមកជួបក្រុមគ្រួសាររបស់នាង។ គាត់បានពន្យល់ថា កូនៗនាង អាចរស់នៅក្នុងមណ្ឌលនោះដោយឥតបង់ប្រាក់ និង



កុមារម្នាក់ក្នុងចំណោមកុមារជាច្រើន ដែលត្រូវបានគេសុំយកទៅចិញ្ចឹមនៅប្រទេសអ៊ីតាលី

មានឱកាសរៀនសូត្រ និងមានការងារធ្វើល្អ។ គាត់មិនបាននិយាយអ្វី អំពីសុំកូនយកទៅចិញ្ចឹមនោះទេ។ ម្ដាយឪពុកទាំងពីរ ក៏សម្រេចចិត្ត ទុកកូនច្បង និងកូនពៅ ឲ្យរស់នៅជាមួយអ្នកទាំងពីរ ហើយបញ្ជូន កូនប្អូនពីរនាក់ផ្សេងទៀត ឲ្យទៅរស់នៅក្នុងមណ្ឌលកុមារកំព្រា។ ស្ត្រីជាម្ដាយបានធ្វើដំណើរទៅកាន់មណ្ឌលនោះ ជាមួយនឹងប្រធានមណ្ឌលហើយនិងកូនៗនាង ដោយនាងបានស្នាក់នៅក្នុងមណ្ឌល ចំនួនពីរយប់។ នាងបានឃើញថា ស្ថានភាពនៅក្នុងមណ្ឌល គឺស្រួលរស់នៅ ហើយក្មេងៗ មើលទៅ គឺទទួលបាន ការចិញ្ចឹមបីបាច់បានល្អ ដូច្នេះនាងបានរីករាយនឹងទុក ឲ្យកូនៗទាំងនោះ ស្នាក់នៅក្នុងមណ្ឌល។

ពេលនាងចាកចេញពីមណ្ឌល ប្រធានមណ្ឌលបានឲ្យប្រាក់នាង ចំនួន១០០ដុល្លារ និងទូរស័ព្ទដៃមួយគ្រឿង ដើម្បីអាចឲ្យនាងរក្សាទំនាក់ទំនង ជាមួយមណ្ឌល។ ប្រធានមណ្ឌលក៏បានប្រគល់ឲ្យនាងនូវទម្រង់ឯកសារមិនទាន់បំពេញចំនួនពីរច្បាប់ សម្រាប់កូននីមួយៗ ហើយបានប្រាប់នាងឲ្យយកឯកសារ ទាំងនេះ ទៅឲ្យអាជ្ញាធរបំពេញ ពីព្រោះគាត់ត្រូវការការអនុញ្ញាតពីអាជ្ញាធរទាំងនោះ ដើម្បីទទួលយកកុមារឲ្យមករស់នៅក្នុងមណ្ឌល។ គាត់បាននិយាយថា អាជ្ញាធរនឹងដឹងថា នឹងត្រូវធ្វើយ៉ាងម៉េចទៅលើឯកសារនេះ។ នាងបានយកឯកសារទៅឲ្យប្រធានភូមិឲ្យជួយបំពេញបែបបទ ហើយប្រធានភូមិនោះបានប្រាប់ឲ្យនាង និងស្វាមីនាង ចុះហត្ថលេខាលើឯកសារ។ បន្ទាប់មក នាងបានយកឯកសារ ទៅជួបមេឃុំដើម្បីឲ្យមេឃុំចុះហត្ថលេខា។ នាងមិនចេះអាន ឬសរសេរអក្សរនោះទេ ប៉ុន្តែទាំងប្រធានភូមិ និងមេឃុំ មិនបានពន្យល់នាង ពីអ្វីដែលបានសរសេរនៅក្នុងឯកសារទាំងនេះនោះទេ។

**នាងបានប្រាប់ប្រធានមណ្ឌលថា នាងមិនចង់ឲ្យកូនទៅរស់នៅមណ្ឌលវិញ ឬក៏ទៅបរទេសទេ។ ប្រធានមណ្ឌលនោះ បាននិយាយថា ហួសពេលហើយដែលម្ដាយឪពុកចង់ផ្លាស់ប្ដូរចិត្ត ដោយសារក្រដាសស្នាមត្រូវបានរៀបចំរួចរាល់ហើយ ហើយថាលោកនឹងមានបញ្ហា ប្រសិនលោកមិនមានកុមារឲ្យគេសម្រាប់យកទៅចិញ្ចឹម។**

នាងបានយកឯកសារទាំងនោះ ឲ្យប្រធានមណ្ឌលកុមារកំព្រានៅភ្នំពេញវិញ។ បន្ទាប់មក នាងបានយកប្រាក់ ១០០ដុល្លារនោះ ដើម្បីឡើងមកសួរសុខទុក្ខ កូនៗ បីទៅបួនដង ក្នុងរយៈពេលពីរបីខែក្រោយមក។ ពីរខែបន្ទាប់ពីកុមារបានទៅរស់នៅក្នុងមណ្ឌល ប្រធានមណ្ឌលបានទូរស័ព្ទទៅនាង ដោយបានប្រាប់នាងថា មានជនបរទេសមួយចំនួន ចង់សុំកូននាង យកទៅចិញ្ចឹម។ ប្រធានមណ្ឌលនោះ បានប្រាប់នាងថា ប្រសិនបើកូនៗទាំងនោះមានសំណាងល្អ ពួកគេនឹងអាចទៅរស់នៅបរទេស។ នាងមិនយល់ពីរឿងនេះទេ ហើយបានសុំឲ្យប្រធានមណ្ឌល ជួយពន្យល់។ គាត់ បាននិយាយថា រឿងនេះមានន័យថា កូនៗនាងអាចនឹងទៅរស់នៅក្រៅប្រទេសជាមួយគ្រួសារបរទេសមួយ ហើយអាចទៅសាលារៀននៅទីនោះ។ លោកបានពន្យល់ថា មណ្ឌលនឹងនៅតែអាចទាក់ទងជាមួយក្រុមគ្រួសារបរទេសនោះ បានដដែល ហើយថាគ្រួសារបរទេសនោះ នឹងផ្ញើព័ត៌មានពីកូនៗ រៀងរាល់ប្រាំមួយខែម្ដង ។ លោកក៏បានបញ្ជាក់ទៀតថា ពេលកូនៗទាំងនោះអាយុ១៥ឆ្នាំ ពួកគេនឹងអាច

វិលត្រឡប់មកប្រទេសកម្ពុជា ជាមួយឪពុកម្តាយចិញ្ចឹម ហើយនៅពេលពួកគេអាយុ១៨ឆ្នាំ ក្មេងៗទាំងនោះអាចមកកម្ពុជាដោយខ្លួនឯងបាន។ នាងបានពិភាក្សាពីរឿងនេះជាមួយស្វាមីនាង ហើយអ្នកទាំងពីរ បានយល់ព្រមឲ្យកូនទៅរស់នៅបរទេស។

ភ្លាមៗ បន្ទាប់ពីនោះមក កូនៗទាំងនោះបានទៅលេងផ្ទះនាថ្ងៃបុណ្យភ្ជុំបិណ្ឌ។ ម្តាយឪពុក បានសន្យាថានឹងឲ្យកូនទៅមណ្ឌល កុមារកំព្រាវិញ បន្ទាប់ពីភ្ជុំបិណ្ឌហើយ។ ក៏ប៉ុន្តែអំឡុងពេលកូនៗមកលេងផ្ទះ ម្តាយឪពុកបានប្តូរចិត្ត អំពីរឿងឲ្យកូនទៅរស់នៅឯបរទេសនេះ។ ពួកគេព្រួយបារម្ភថា ពេលកូនៗទៅក្រៅបរទេស កូនៗរបស់អ្នកទាំងពីរ នឹងមិនត្រឡប់មកប្រទេសកម្ពុជាវិញទេ ដូច្នេះអ្នកទាំងពីរ បានសម្រេចឈប់យកកូនទៅរស់នៅមណ្ឌលវិញ។ អ្នកទាំងពីរបានយកកូនតូចៗបីនាក់ ឲ្យទៅរស់នៅជាមួយសាច់ញាតិ ហើយទុកកូនស្រីពៅឲ្យនៅជាមួយ។ ពេលភ្ជុំបិណ្ឌហើយ នៅពេលដែលកុមារទាំងនោះ មិនបានត្រលប់ទៅមណ្ឌលកុមារកំព្រាវិញ ប្រធានមណ្ឌលបានមកយកកូនៗ ទាំងនោះទៅមណ្ឌលវិញ។ ម្តាយបានយកកូនពៅ ទៅលាក់នៅក្នុងចំការកៅស៊ូ ប៉ុន្តែអ្នកជិតខាងបានប្រាប់ប្រធានមណ្ឌល ពីកន្លែងដែលកូនស្រីពៅលាក់ខ្លួន។ កូនរបស់នាងម្នាក់ កំពុងលេងនៅមិនឆ្ងាយប៉ុន្មានពីម្តាយ ហើយពេលប្រធានមណ្ឌល បានមកដល់ លោកបានចាប់លើកយកកូននោះ។

ហេតុនេះ ម្តាយបានយល់ព្រមឲ្យ ប្រធានមណ្ឌលអាចយកកូនពៅនាងទៅបាន។ ប្រធានមណ្ឌលបានប្រាប់នាងឲ្យប្រមូលកូនៗផ្សេងទៀតមក ហើយបញ្ជូនពួកគេទៅភ្នំពេញ។ ម្តាយឪពុក បានយល់ព្រមធ្វើតាមការស្នើសុំរបស់ប្រធានមណ្ឌល ដោយសារអ្នកទាំងពីរ ព្រួយបារម្ភថាកូនពៅនោះ នឹងទៅរស់នៅបរទេសតែម្នាក់ឯង។ អ្នកទាំងពីរបានគិតថាកូនៗទាំងអស់ នឹងត្រូវបញ្ជូនទៅរស់នៅក្រៅប្រទេសជាមួយគ្នា ហើយពួកគេអាចមើលថែគ្នាបាន។

ក្រោយមក ម្តាយបានទៅលេង កូនពីរបីដងទៀត។ ប្រធានមណ្ឌល មិនបានប្រាប់នាងថា ពេលណាដែលកូនៗទាំងនោះ នឹងត្រូវចាកចេញទៅបរទេសនោះទេ ប៉ុន្តែពីរបីសប្តាហ៍បន្ទាប់ កូនៗទាំងនោះ បានចាកចេញទៅម្តងមួយៗ។ ម្តាយបានដឹងពីដំណឹងនេះ ទាល់តែពេលនាងទូរស័ព្ទទៅពួកគេ ឬពេលទៅលេងកូនៗ ទាំងនោះប៉ុណ្ណោះ។ ពេលដែលកូនៗបានទៅបាត់អស់ហើយ នាងនៅតែបន្ត ទាក់ទងជាមួយ ប្រធានមណ្ឌល ហើយប្រធានមណ្ឌលនោះ បានឲ្យនាង នូវរូបថតកូនៗ ទាំងនោះច្រើនសន្លឹក ដែលត្រូវបានថតមុនពេល កូនៗទាំងនោះ ចាកចេញ។ មិនយូរប៉ុន្មានក្រោយមក ប្រធានមណ្ឌលនោះបានឲ្យរូបថតមួយចំនួនរបស់កូននាងម្នាក់ ដែលគេផ្ញើមកពីបរទេស។ នាងមិនបានទទួលរូបថតផ្សេងទៀតឬដំណឹងណាមួយពីកូនពីរនាក់ផ្សេងទៀតនោះទេ។

ជាច្រើនឆ្នាំក្រោយមក ម្តាយនៅបន្តទាក់ទងជាមួយប្រធានមណ្ឌលកុមារកំព្រា តាមទូរស័ព្ទ ហើយលោកតែងប្រាប់នាងថា កូនៗទាំងនោះ សុខសប្បាយជាទេ ហើយបានប្រាប់នាង កុំឲ្យព្រួយបារម្ភ។ នៅឆ្នាំ២០១៦ នាងមិនអាចទាក់ទងតាមទូរស័ព្ទទៅប្រធានមណ្ឌល បានទៀតទេ ហើយនាងមានការព្រួយបារម្ភជាខ្លាំង។ នាង មិនដឹងត្រូវទៅទាក់ទងនរណាដើម្បីសុំជំនួយនោះទេ តែជាសំណាងល្អ នាងបានជួបបុគ្គលិកអង្គការលីកាដូម្នាក់ ដែលក្រោយមកអង្គការលីកាដូ បានទទួលដោះស្រាយករណីនេះ។

បុគ្គលិកអង្គការលីកាដូ បានរកឃើញថាកុមារទាំងនោះត្រូវបាន គេយកទៅចិញ្ចឹមនៅប្រទេសអ៊ីតាលី។ កំឡុងពេលឃ្លាំមើល អង្គការលីកាដូ ទទួលបានលិខិតជាច្រើនច្បាប់ ដែលត្រូវបានផ្ញើចេញនៅ ឆ្នាំ២០០៨ និង ២០០៩ ដោយក្រសួងសង្គមកិច្ច និងទីស្តីការគណៈរដ្ឋមន្ត្រីទាក់ទងនឹងសកម្មភាព សុំកូនកុមារទាំងបី។ លិខិតទាំងនោះ បានបញ្ជាក់ថា ដោយផ្អែកតាម ការស្រាវជ្រាវដោយក្រសួងសង្គមកិច្ច កុមារទាំងនោះ ជាក្មេងកំព្រា ដែលត្រូវបានម្តាយឪពុកបោះបង់ចោល។ ដោយសារ ប្រធានមណ្ឌលកុមារកំព្រានោះ បានដឹងយ៉ាងច្បាស់ថាកុមារទាំងនោះ មិនមែនជាក្មេង ដែលត្រូវបានម្តាយឪពុកបោះបង់ចោលនោះ អាចសន្និដ្ឋានថា ការស្រាវជ្រាវមួយ ដែលត្រឹមត្រូវ និងម៉ត់ចត់ពីប្រវត្តិកុមារ មិនត្រូវបានធ្វើឡើងនោះទេ។ លិខិតទាំងនោះ ក៏មានសរសេរថ្ងៃខែឆ្នាំកំណើតក្លែងក្លាយរបស់កុមារទាំងបីនោះដែរ ដោយអាយុកុមារម្នាក់ៗ ត្រូវបានគេបន្ថយចំនួនបួនឆ្នាំ បីឆ្នាំ និងមួយឆ្នាំ។ ដូចនេះ គឺទំនងជាសំបុត្រកំណើតក្លែងក្លាយ ត្រូវបានគេធ្វើឡើងសម្រាប់កុមារទាំងនោះ ដើម្បីសម្រួលដល់ដំណើរការសុំកូន។ ករណីខាងលើនេះ គឺជាករណីរំលោភលើអនុសញ្ញា អន្តរជាតិ ស្តីពីសិទ្ធិកុមារ។ ករណី ដែលកុមារដែលត្រូវបាន គេបន្ថយអាយុចំនួនបួនឆ្នាំ ដោយបន្ថយពីប្រាំបួនមកប្រាំឆ្នាំ។ ដូចនេះយោងតាមច្បាប់ ជាធរមាននាពេលនោះ គ្មានកុមារណាម្នាក់ ដែលមានអាយុ លើសពីប្រាំបីឆ្នាំ ត្រូវបានគេយកទៅចិញ្ចឹមនោះទេ។[២៩]

[២៩] មាត្រា១១០, ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

អនុសញ្ញាទីក្រុង ឡាអេ បានចូលជាធរមាននៅប្រទេសកម្ពុជា កាលពីឆ្នាំ២០០៧ គឺរយៈពេលមួយឆ្នាំមុនសកម្មភាពសុំកូននេះកើតឡើង។ អនុសញ្ញានេះ តម្រូវឲ្យម្ដាយឪពុក គួរទទួលបានការប្រឹក្សា និងពន្យល់ពីផលប៉ះពាល់នៃសកម្មភាពសុំកូន ជាពិសេសថា តើការសុំកូននោះ នឹងនាំឲ្យមានការបញ្ចប់ទំនាក់ទំនងផ្លូវច្បាប់ ជាមួយកូនៗរបស់ម្ដាយឪពុកនោះឬយ៉ាងណា។ អនុសញ្ញានេះ ក៏តម្រូវឲ្យមានការយល់ព្រមដោយសេរី និងអាចលុបចោលការយល់ព្រមនោះវិញបាន ដោយម្ដាយឪពុកក្មេង ដើម្បីឲ្យសកម្មភាពសុំកូននេះ អាចត្រូវបានធ្វើឡើង។ កុមារក៏តម្រូវឲ្យទទួលបាន ការប្រឹក្សា ហើយបំណង និងមតិយោបល់របស់កុមារទាំងនោះ គួរត្រូវបាន យកទៅពិចារណា។ លក្ខខណ្ឌតម្រូវទាំងនេះ គឺមានសារៈសំខាន់នៅប្រទេសកម្ពុជា ដែលកុមារតែងតែត្រូវបានម្ដាយឪពុកឲ្យទៅរស់នៅ ជាមួយសាច់ញាតិ ឬក៏មិត្តភក្តិ ដែលអាចជួយចិញ្ចឹម និងអាចឲ្យកុមារបានចូលរៀន ប៉ុន្តែមិនដែលមានប្រវត្តិនៃសកម្មភាពសុំកូនពេញលេញនោះទេ។ ក៏ប៉ុន្តែក្នុងករណីនេះ លក្ខខណ្ឌតម្រូវឲ្យមាន ការប្រឹក្សាយោបល់មិនត្រូវបានធ្វើឡើងនោះទេ ហើយម្ដាយឪពុក ជាការពិតក៏តែងតែទទួលបានព័ត៌មាន មិនពិត ដែលធ្វើឲ្យអ្នកទាំងពីរជឿថា ទំនាក់ទំនងរបស់ពួកគេ ជាមួយកូន នឹងនៅតែនៅមានបន្តទៀត។

កាលពីខែឧសភា ឆ្នាំ២០១៧ អង្គការលីកាដូ បានសរសេរលិខិតជូនក្រសួងសង្គមកិច្ច ដោយស្នើសុំក្រសួងចែករំលែកព័ត៌មាន ដែលក្រសួងមាន ទាក់ទងនឹងសកម្មភាពសុំកូនទាំងបួន។ បុគ្គលិកអង្គការលីកាដូ បានតាមដានករណីទាំងនេះដោយមានការចុះទៅមើលទីតាំងផ្ទាល់ និងសន្ទនាតាមទូរស័ព្ទ ហើយនៅពេលមួយនោះ ក្រសួងបានប្រាប់ថា លិខិតឆ្លើយតប មួយត្រូវបានគេព្រាងរួចហើយ ក៏ប៉ុន្តែ រហូតមកពេលនេះ លិខិតនោះលីកាដូ នៅមិនទាន់ទទួលបាននៅឡើយទេ។

នៅអំឡុងពេលសរសេររបាយការណ៍នេះ អង្គការលីកាដូ បានទទួលករណីបីផ្សេងទៀត ដែលពាក់ព័ន្ធនឹងមណ្ឌលកុមារកំព្រាដដែលនេះ ប៉ុន្តែបុគ្គលិកអង្គការលី កាដូ នៅមិនទាន់មានឱកាស ដើម្បីឃ្លាំមើលករណីនេះឲ្យបានពេញលេញនៅឡើយទេ។

មានការទទួលស្គាល់ជាអន្តរជាតិ នូវលក្ខខណ្ឌតម្រូវដើម្បីធានាថា សកម្មភាពសុំកូនអន្តរប្រទេស គឺត្រូវបានធ្វើឡើង ដើម្បីផ្តល់អត្ថប្រយោជន៍ដ៏ល្អបំផុត ដល់កុមារដែលនឹងត្រូវបានគេសុំយកទៅចិញ្ចឹម ហើយរដ្ឋនីមួយៗត្រូវចាត់វិធានការ ដើម្បីទប់ស្កាត់ ការបញ្ជូនកុមារចេញពីប្រទេសកម្ពុជាដោយលួចលាក់ ការលក់ និងការជួញដូរកុមារ។ ទាំងនេះគឺជាគោលបំណងចំបង នៃអនុសញ្ញាទីក្រុងឡាអេ។ ទោះបីជាមានយន្តការអន្តរជាតិ និងមានករណីជាច្រើន អំពីសកម្មភាពសុំកូនដោយក្លែងបន្លំបានកើតឡើងទូទាំងពិភពលោកក៏ដោយ ក៏មិនមាននីតិវិធីដែលត្រូវបានទទួលយកជាលក្ខណៈអន្តរជាតិ ក្នុងការដោះស្រាយវិបត្តិដ៏រ៉ាំរ៉ៃនេះដែរ។ អនុសញ្ញាទីក្រុង ឡាអេក៏មិនបានចែងពីលក្ខខណ្ឌផ្សេងទៀត ក្រៅពីលក្ខខណ្ឌដែលតម្រូវឲ្យរដ្ឋនីមួយៗ "ចាត់វិធានការសមរម្យ" នោះដែរ។ ហើយក៏មិនមានវិធីណាមួយច្បាស់លាស់ ដើម្បីអនុវត្ត នៅពេលដែលករណីបែបនេះ កើតឡើង ហើយថែមទាំង មិនមានបន្ទុកណាមួយ ដាក់ទៅលើរដ្ឋ ដើម្បីឆ្លើយតបទៅនឹងរឿងនេះនោះដែរ។[៣០]

រយៈប៉ុន្មានឆ្នាំចុងក្រោយនេះ មានការទទួលស្គាល់មួយចំនួនពីភាពចាំបាច់ ដែលរដ្ឋ ត្រូវអនុវត្តថែមទៀតដើម្បីកំណត់អត្តសញ្ញាណ ទប់ស្កាត់ និងឆ្លើយតប ទៅនឹងការអនុវត្តសុំកូនអន្តរប្រទេសខុសច្បាប់។ នៅឆ្នាំ២០១០ ស្ថាប័នទទួលបន្ទុក អនុសញ្ញាទីក្រុងឡាអេ បានបង្កើតក្រុមការងារដើម្បីទប់ស្កាត់ និងដោះស្រាយ ការអនុវត្តខុសច្បាប់ដើម្បី ជាការឆ្លើយតប ទៅនឹង ការទទួលស្គាល់នៃភាពចាំបាច់នេះ។ក្នុងឆ្នាំ២០១៦ក្រុមការងារនេះបានចេញផ្សាយអនុសាសន៍ មួយចំនួន ដោយសង្កត់បញ្ជាក់ពីសារៈសំខាន់ នៃការលើកយកបញ្ហា ការអនុវត្តខុសច្បាប់មកជជែកពិភាក្សា និងបានទទួលស្គាល់ពីតម្លៃ នៃការបង្កើតយន្តការរាយការណ៍ និងដាក់ពាក្យបណ្តឹងនៅក្នុងបណ្តារដ្ឋដែលបញ្ជូនកុមារ និង រដ្ឋដែលទទួលកុមារ។ អនុសាសន៍បានលើកឡើងថា ការបង្កើតវិធានការគំរូមួយ ដើម្បីឆ្លើយតបទៅនឹង ករណីជាក់លាក់មួយចំនួនពាក់ព័ន្ធ នឹងការអនុវត្តខុសច្បាប់ គួរតែមានការបញ្ចូលការប្រឹក្សាយោបល់ សំណងការខូចខាត និង ការដាក់ទណ្ឌកម្ម។ ក្រុមការងារដដែលនេះ ក៏បានទទួលស្គាល់ពីសារសំខាន់ នៃការលើកឡើងពី តម្រូវការរបស់ជនរងគ្រោះតាមរយៈការផ្តល់ការប្រឹក្សា ការទទួលស្គាល់កំហុស និងការតភ្ជាប់ទំនាក់ទំនងឡើងវិញ រវាងកូនដែលគេយកទៅចិញ្ចឹម និងម្តាយឪពុកបង្កើត។[៣១] អនុសាសន៍ទាំងនេះត្រូវបាន គេស្វាគមន៍ ក៏ប៉ុន្តែមកដល់ពេលនេះ មិនទាន់ឃើញ មានការចាត់វិធានការ ជាដុំកំភួនណាមួយ ត្រូវបានគេយកមកអនុវត្តនៅឡើយ។

ការខ្វះខាត នៃនីតិវិធីច្បាស់លាស់ និងឯកភាពគ្នាមួយ ធ្វើឲ្យអង្គការ លីកាដូ ជួបការលំបាកជាខ្លាំង ដើម្បីដោះស្រាយករណីទាំងបី ដែលបានរៀបរាប់នៅខាងលើនេះ។ ក្រសួងសង្គមកិច្ច មិនទាន់ឆ្លើយតបនឹងលិខិតរបស់អង្គការលីកាដូ កាលពីខែឧសភា ឆ្នាំ២០១៧ ដែលបានស្នើសុំព័ត៌មានទាក់ទងនឹងករណីទីបីនៅឡើយ។ ជាងនេះទៅទៀត នៅខែតុលា ឆ្នាំ២០១៧ អង្គការលីកាដូ បានផ្ញើព័ត៌មានលម្អិត ស្តីពីករណីនេះ ដោយភ្ជាប់ជាមួយនឹងភស្តុតាងពាក់ព័ន្ធ ដែលបង្ហាញថា សកម្មភាពសុំកូននោះត្រូវបានធ្វើឡើងដោយក្លែងបន្លំ ជូនគណៈកម្មាការអ៊ីតាលីស្តីពីសុំកូនអន្តរប្រទេស ជាស្ថាប័នដែលទទួលខុសត្រូវស្ថិតក្រោមអនុសញ្ញាទីក្រុងឡាអេ សម្រាប់រៀបចំបទបញ្ញត្តិនានា ចំពោះសកម្មភាព សុំកូនអន្តរប្រទេសទាំងអស់។ រហូតមកដល់ពេលនេះ គណៈកម្មាការនេះនៅមិនទាន់បានឆ្លើយតប នឹងលិខិតនោះនៅឡើយទេ។ នៅខែវិច្ឆិកា អង្គការលីកាដូ បានសរសេរលិខិតជូន ក្រសួងយុត្តិធម៌ នៃប្រទេសអូទ្រីស ទាក់ទងនឹងករណីទីពីរ។ ក្រសួងបានទទួលយកលិខិត ហើយក្នុងខែមីនាឆ្នាំ២០១៨ ស្ថាប័ននេះបានឆ្លើយតបថា ប្រហែលអាចមានលទ្ធភាពក្នុងការជួយលើករណីនេះ។ អង្គការលីកាដូ នៅតែបន្តការតាមដានលើករណីនេះយ៉ាងយកចិត្តទុកដាក់ ដើម្បីជួយដល់ស្ត្រីជាម្តាយរបស់កុមារទាំងនោះ។

---

៣០ មាត្រា៣៣, អនុសញ្ញាទីក្រុងឡាអេស្តីពីសុំកូនអន្តរប្រទេស

៣១ សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់ក្រុមការងារដើម្បីទប់ស្កាត់ និងដោះស្រាយការអនុវត្តខុសច្បាប់ ក្នុងសកម្មភាពសុំកូនអន្តរប្រទេស (កិច្ចប្រជុំថ្ងៃទី១៣ ដល់ទី១៥ ខែតុលា ឆ្នាំ២០១៦), សន្និសីទក្រុងឡាអេស្តីពីច្បាប់អន្តរជាតិឯកជន, ខែតុលា ឆ្នាំ២០១៦, https://assets.hcch.net/docs/536b1d4d-6ed1-4d42-8511-e1676d17464a.pdf.

ករណីដែលបានរៀបរាប់ខាងលើនេះ ផ្តល់ជាភស្តុតាងបង្ហាញថាការក្លែងបន្លំ និងអំពើដែលត្រូវបានគេអះអាងថាជា អំពើពុករលួយ បានបន្តកើតមានឡើងនៅក្នុងប្រព័ន្ធសុំកូនអន្តរប្រទេសនៅកម្ពុជានៅក្នុង ទសវត្សរ៍ឆ្នាំ ២០០០។ ចំនួនករណី ដែលត្រូវបានរាយការណ៍ មកអង្គការ លីកាដូ មកដល់ពេលនេះ នៅមានកម្រិតទាប ដូច្នេះ ទំហំនៃអំពើក្លែងបន្លំ និងអំពើដែលត្រូវបានគេអះអាងថា ជាអំពើពុករលួយ ពិតជាពិបាកក្នុងការធ្វើការវាស់វែង។ ក៏ប៉ុន្តែ ផ្អែកលើភស្តុតាង ដែលមានស្រាប់ ហើយដែលត្រូវបានរកឃើញ ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក និង ប្រទេសហូឡង់ ករណីទាំងបីនេះ ទំនងជាករណីចំនួនតូចក្នុងចំណោម ករណីជាច្រើន។ នេះអាចថាចំនួននៃករណីដែលត្រូវបាន រាយការណ៍ មានកម្រិតទាប ដោយសារ ជនរងគ្រោះពីអំពើ សុំកូនក្លែងបន្លំ គិតថា មិនមានវិធីអ្វីអាច ដោះស្រាយបាន ឬ អ្នកទាំងនោះ មិនដឹងពីកន្លែង ដែលអាចពឹងពាក់សុំ ជំនួយបាន។ ដោយផ្អែកលើការណ៍ ដែលកុមាររាប់ពាន់នាក់ ត្រូវបានគេយកទៅចិញ្ចឹមអស់ជាច្រើនឆ្នាំមកនេះ បញ្ហានេះទំនងថា ប្រសិនបើម្តាយឪពុកបង្កើត បានដឹងពីអ្នក ដែលអាចពឹងពាក់សុំជំនួយបាន នោះនឹងមានម្តាយឪពុកជាច្រើន នឹងទៅរកជំនួយ។

អង្គការលីកាដូ គាំទ្រអនុសាសន៍របស់ "ក្រុមការងារដើម្បីទប់ស្កាត់ និងដោះស្រាយការអនុវត្តខុស ច្បាប់" ប៉ុន្តែកង្វះខាតការអនុវត្តជាក់ស្តែង ធ្វើឲ្យមានការ ខកចិត្តយ៉ាងខ្លាំង។ ករណីទាំងបី ដែលត្រូវបានពិពណ៌នា ខាងលើនេះ បង្ហាញពីភាពចាំបាច់នៃវិធានការជាក់លាក់ ដើម្បីអនុវត្ត ដោយសារនេះជាស្ថានភាពបន្ទាន់។ ក្រុមគ្រួសារដែលបានត្រូវគេយកកូនចេញទៅរងនូវភាពឈឺចាប់ អស់រយៈពេលជាច្រើនមកហើយដោយ មិនបានទទួលព័ត៌មាន ណាមួយពីសុខទុក្ខរបស់កូនៗអ្នកទាំងនោះ ហើយការព្យាយាមស្វែងរកព័ត៌មានអំពីកូនៗរបស់អ្នកទាំងនោះ តែងត្រូវបានគេបដិសេធ ឬ ក៏មិនត្រូវបានគេយកចិត្តទុកដាក់នោះទេ។

ករណី ទាំងនេះ ក៏បានបង្ហាញពីភាពមិនយកចិត្តទុកដាក់ទាំងស្រុង ចំពោះសិទ្ធិរបស់ម្តាយឪពុក និងកុមារដែលធ្លាក់ចូលក្នុងប្រព័ន្ធសុំកូនអន្តរប្រទេសនេះ ហើយបង្ហាញ ពីរបៀបនៃការកេញប្រវ័ញ្ច លើពលរដ្ឋដែលមានជីវភាពក្រីក្រ និងមានកម្រិតនៃការអប់រំតិចតួច ពីសំណាក់អ្នកដែលមាន តួនាទីក្នុងការការពារពលរដ្ឋទាំងនោះ។ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសទទួលកុមារ គួរតែទទួលស្គាល់នូវភាពខ្វះខាតរបស់ខ្លួន និងត្រូវធានាថា មិនឲ្យមាន ករណីបែបនេះ កើតឡើងវិញទៀតឡើយ។ ម្តាយឪពុក និង កុមារដែលបានព្រាត់ប្រាសគ្នា ដោយសារ ដំណើរការ សុំកូននេះ គួរទទួលបានការសុំទោសពីស្ថាប័នរដ្ឋដែលពាក់ព័ន្ធ និងការទទួលស្គាល់ពីទុក្ខវេទនា ដែលអ្នកទាំងនោះបានទទួលរង។ នៅពេលដែលមិនមានវិធីណាមួយ ដើម្បីកែប្រែកំហុស ពីអតីតកាលបាន ចំណុចសំខាន់ជាងគេ គឺរដ្ឋាភិបាលពាក់ព័ន្ធត្រូវផ្តល់នូវសំណងការខូចខាត ដែលនឹងជួយសម្រាលទុក្ខសោក ដែលបានកើតឡើងជាច្រើនឆ្នាំមកនេះ។

## អនុសាសន៍

យើងខ្ញុំសង្ឃឹមថា៖

►►► ក្រសួងសង្គមកិច្ច និងរដ្ឋាភិបាលប្រទេសអ៊ីតាលី នឹងឆ្លើយតបជាបន្ទាន់ ទៅនឹងសំណើរសុំការជួយគាំទ្រពីរដ្ឋាភិបាលទាំងនេះ ក្នុងការចាត់វិធានការជាសកម្មភាពមួយចំនួន ដើម្បីផ្តល់ការជួសជុល សំណងដល់ជនរងគ្រោះ និងដាក់ទណ្ឌកម្ម ដល់អ្នកដែលទទួលខុសត្រូវលើបញ្ហាសុំកូនក្លែងបន្លំទាំងនេះ។

►►► រាជរដ្ឋាភិបាលកម្ពុជា នឹងចេញនូវលិខិតទទួលស្គាល់ជាសាធារណៈមួយ ចំពោះកំហុសឆ្គងដែលអាជ្ញាធររដ្ឋបានប្រព្រឹត្តពីអតីតកាល ពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស ការទទួលស្គាល់កំហុសចំពោះអ្នកទាំងអស់ដែលរងគ្រោះ និងការអញ្ជើញក្រុមគ្រួសារដែលប៉ះពាល់ ឲ្យមកប្រាប់ពីរឿងរ៉ាវរបស់អ្នកទាំងនោះ និងស្វែងរកសំណងការខូចខាត។

►►► រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីប្រទេសដែលទទួលកុមារ នឹងបង្កើតគណៈកម្មាធិការស៊ើបអង្កេតពិសេសមួយ ដើម្បីជួយដល់ក្រុមគ្រួសារកម្ពុជា ដែលរងគ្រោះដោយសកម្មភាពសុំកូនក្លែងបន្លំ ក្នុងការស្វែងរកទីតាំងរស់នៅរបស់កូនៗអ្នកទាំងនោះ និងជួយភ្ជាប់ទំនាក់ទំនងឡើងវិញរវាងម្តាយឪពុក និងកូន។

►►► ប្រទេសទទួលកុមារ គួរលើកកម្ពស់ការយល់ដឹងពីបញ្ហានេះ នៅក្នុងប្រទេសរបស់ពួកគេ អំពីប្រវត្តិនៃសកម្មភាពសុំកូនក្លែងបន្លំនៅកម្ពុជា និងបង្កើតយន្តការមួយចំនួនសម្រាប់កុមារកម្ពុជាដែលត្រូវបានគេយកទៅចិញ្ចឹម ក្នុងការស្រាវជ្រាវពីសាវតារបស់កុមារទាំងនោះ និងបង្កើតទំនាក់ទំនងឡើងវិញជាមួយម្តាយឪពុកបង្កើត ប្រសិនបើកុមារចង់។

►►► រដ្ឋាភិបាលនៃប្រទេសទទួលយកកុមារ គួរបង្កើតការស៊ើបអង្កេតឯករាជ្យ លើពលរដ្ឋរបស់ខ្លួនដែលបានធ្វើខុស ឬក៏ទីភ្នាក់ងារសុំកូន ដែលពាក់ព័ន្ធនឹងសកម្មភាពសុំកូនអន្តរប្រទេស នៅប្រទេសកម្ពុជា ដោយមានការដាក់ទោសទណ្ឌរដ្ឋបាល ឬឧក្រិដ្ឋ តាមកម្រិតទោស។

►►►រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលប្រទេសទទួលកុមារ នឹងធានាថា គ្មានសកម្មភាពសុំកូនអន្តរប្រទេសណាមួយកើតឡើងទៀតឡើយ លុះត្រាណា ប្រព័ន្ធដោះស្រាយ និងការស៊ើបអង្កេតមួយ ត្រូវបានអនុវត្ត ហើយវិធានការសុវត្ថិភាពត្រូវបានយកអនុវត្ត ដើម្បីធានាថា កំហុសអតីតកាល នឹងមិនអាចកើតមានឡើងវិញឡើយ។

►►► អនុសញ្ញាក្រុងឡាអេស្តីពីច្បាប់អន្តរជាតិឯកជន ស្ថាប័នដែលទទួលខុសត្រូវលើអនុសញ្ញាក្រុងឡាអេ គួរបង្កើតឲ្យបានរួសរាន់លើដំណើការគំរូ ដើម្បីដោះស្រាយការអនុវត្តខុសច្បាប់ ក្នុងសកម្មភាពសុំកូនអន្តរប្រទេស និងគួរដាក់ការអនុវត្តនេះ ជាលក្ខខណ្ឌតម្រូវមួយដល់ហត្ថលេខីទាំងអស់ នៃអនុសញ្ញាក្រុងឡាអេនេះ៕

www.licadho-cambodia.org